# ពិធីពុទ្ធាភិសេក

## THE CEREMONIAL BLESSING OF THE BUDDHA’S STATUES

រៀបរៀងដោយ

អគ្គទត្តោ. គល់-សុភាព

ព.ស ២៥៦៣ គ.ស ២០១៩

# ពិធីពុទ្ធាភិសេក

## THE CEREMONIAL BLESSING
## OF THE BUDDHA'S STATUES


រៀបរៀងដោយ

អគ្គទត្តោ. **គល់~សុភាព**



ព.ស. ២៥៦៣ គ.ស. ២០១៩

សម្រាប់ជាធម្មទាន

# ប្រវត្តិសៀវភៅ

| | | |
|---|---|---|
| ឈ្មោះសៀវភៅ | : | **ពិធីពុទ្ធាភិសេក** |
| អ្នករៀបរៀង | : | ភិក្ខុ អគ្គទត្តោ. **គល់-សុភាព** |
| ស្ថានទីធ្វើ | : | វត្តតបោស្សសាន (ព្រៃស្នាច់), ខេត្តកំពង់ឆ្នាំង |
| កាលបរិច្ឆេទធ្វើ | : | ខែមិថុនា គ.ស. ២០១៩, ព.ស. ២៥៦៣ |
| អ្នកជួយពិនិត្យ | : | គុណម្ចាស់ ម៉ោល-សារុន & ឧបាសិកា ហង្ស-សុខា |
| អ្នកវាយអត្ថបទ | : | ភិក្ខុ អគ្គទត្តោ. គល់-សុភាព |
| ពិនិត្យលើកទី២ | : | ថ្ងៃទី២២ ខែកុម្ភៈ គ.ស. ២០២១, ព.ស. ២៥៦៤ |
| ទីតាំងពិនិត្យ | : | វត្តនាគគិរី (ភ្នំរោងដំរី) ខេត្តកំពង់ឆ្នាំង |
| គេហទំព័រ | : | E-mail: kolsopheap839@gmail.com |
| | | Facebook : Kol Sopheap & |
| | | Page : Kol Sopheap - គល់-សុភាព |
| Contact | : | 088 26 94 695 / 016 75 30 89 |

# អារម្ភកថា

សៀវភៅនេះខ្ញុំចងក្រងជាសេចក្តីសង្ខេប តាមដំណើរពុទ្ធប្បត្តិ ត្រង់ចំណុចព្រះអង្គផ្ចាញ់មារនិងត្រាស់ដឹង ដើម្បីជាក្បួនសម្រាប់ប្រើការក្នុងពេលធ្វើបុណ្យពុទ្ធាភិសេក ជាពិសេសសម្រាប់លោកអាចារ្យអ្នកដឹកនាំកម្មវិធី ទៅតាមសម័យកាលបច្ចុប្បន្ន ។ មូលហេតុនាំឲ្យខ្ញុំរៀបរៀងសៀវភៅនេះឡើង ព្រោះថ្ងៃមួយក្នុងពិធីបុណ្យចម្រើនព្រះជន្ម និងពុទ្ធាភិសេក នៅជិតផ្សាររមាស, ខ្ញុំត្រូវបានគេពឹងឲ្យជួយដឹកនាំធ្វើពុទ្ធាភិសេក នៅខាងដើមបឋមយាមនៃរាត្រី ។ ការធ្វើនោះមិនបានប្រពៃសព្វគ្រប់ទេ ព្រោះមិនជំនាញនិងគ្មានក្បួនជាប់តាមខ្លួន ម្យ៉ាងទៀតវាជាកិច្ចរបស់លោកអាចារ្យ ។ ព្រោះការណ៍នោះជាបច្ច័យ ទើបខ្ញុំសម្រេចចិត្តធ្វើក្បួនពុទ្ធាភិសេកសង្ខេបនេះឡើង ដើម្បីជាឯកសារដល់ជនច្រើនគ្នា ព្រោះថាក្នុងបច្ចុប្បន្នសម័យនេះ ពុទ្ធបរិស័ទខ្មែរយើងជាច្រើនតែងនិយមធ្វើបុណ្យពុទ្ធាភិសេក ភ្ជាប់ជាមួយបុណ្យចម្រើនព្រះជន្ម គម្រប់ខួប ឆាកបង្សុកូលជង ។ បើយើងបានចេះស្ទាត់ដោយល្អឬមានក្បួននេះជាប់តាមខ្លួន ការធ្វើនោះនឹងប្រព្រឹត្តទៅដោយរលូន ។

ក្នុងពេលប្រារព្ធពិធី លោកអាចារ្យ គប្បីដឹកនាំពុទ្ធបរិស័ទឲ្យសូត្របាលីនិងសេចក្តីប្រែ ទៅតាមសង្កាត់នីមួយ ៗ ។ បើមានពេលច្រើនគួរពោលគាថា ឬកំណាព្យផ្សេងៗទៀត ដែលទាក់ទងនឹងគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ត្រង់ **បកិណ្ណកធម៌** នៅផ្នែកខាងក្រោយក៏បាន

ដើម្បីនាំឲ្យកើតកុសលសោមនស្សក្រាន់តែក្រៃលែង ។

ខ្ញុំគិតថាសៀវភៅនេះនៅខ្វះចន្លោះច្រើន គឺថាមិនទាន់គ្រប់ជ្រុងជ្រោយក្នុងកិច្ចនៃពុទ្ធាភិសេកទាំងមូលទេ ដូច្នេះសូមអស់លោកជាធម្មកោវិទ ដែលឈ្លាសប្រតិពលក្នុងពិធីកម្មនេះ ជួយកែសម្រួលនិងថែ្លលែលកយ៉ាងណាឲ្យស័ក្តិសមក្នុងកម្មវិធី ប្រព្រឹត្តទៅយ៉ាងប្រពៃដោយខ្លួនឯងផងចុះ ដើម្បីជាទីនាំមកនូវសេចក្តីជ្រះថ្លាចម្រើននូវកុសលដល់ម្ចាស់ដើមបុណ្យនិងពួកពុទ្ធបរិស័ទ ។

ជាទីបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណ ដល់លោកអាចារ្យក្មេង **ហេង-ជុំនិត** បានផ្តល់ឯកសារមួយចំនួនដែលពាក់ព័ន្ធ និង ឧបាសក **សែម-ឃុិន** ជួយផ្តល់យោបល់ ព្រមទាំង គុណម្ចាស់ **ម៉ោល-សារុន** និង ឧបាសិកា សារទេសិកា **ហង្ស-សុខា** ដែលបានជួយពិនិត្យអក្ខរាវិរុទ្ធ ដោយយកចិត្តទុកដាក់ និងស្រលាញ់អក្សរសាស្ត្រខ្មែរ ។

សូមជនានុជនទាំងឡាយក្នុងកម្ពុជរដ្ឋ បានប្រសព្វនូវវឌ្ឍនធម៌ ហើយរួបរួមគ្នាលើកតម្កើងអក្សរសាស្ត្រ កសាងប្រទេសជាតិ និងព្រះពុទ្ធសាសនា ឲ្យបានចម្រើន ជាភិយ្យោភាពតរៀងទៅ ។

វត្តតបោស្នសាន (ព្រៃស្នាច់)
ថ្ងៃពុធ ទី១២ ខែមិថុនា ឆ្នាំ ២០១៩
អគ្គទត្តោ. **គល់~សុភាព**
សមណនិស្សិតពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ខេត្តកំពង់ឆ្នាំង

# សេចក្តីផ្តើម

ពុទ្ធាភិសេក ជាពិធីបុណ្យមួយ ដែលពុទ្ធសាសនិកជននិយមធ្វើជារឿយៗដើម្បីរម្លឹកនូវការឈ្នះមាររបស់ព្រះបរមពោធិសត្វ និងការបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធក្នុងលោក ។ មិនតែប៉ុណ្ណោះទេ ពុទ្ធ -បរិស័ទយើងតែងភ្ជាប់បុណ្យពុទ្ធាភិសេកនេះ ជាមួយបុណ្យចម្រើនព្រះជន្ម ឆាកបង្សុកូល ទៀតផង ប៉ុន្តែពិធីនេះគេតែងប្រារព្ធនៅប្រហែលជាម៉ោង ៧ យប់ ។ ម្ចាស់បុណ្យបានរៀបចំបុស្បុកតូចល្មមនៅទីបំផុតរោងផ្នែកខាងលើ និងមានតម្កល់ព្រះពុទ្ធរូបអង្គថ្មី ឬព្រះបត់លើទីតាំងនោះផង ។ ខាងមុខពុទ្ធរូបផ្នែកខាងក្រោម មានរៀបចំគ្រឿងសក្ការបូជាផ្សេងៗមានផ្កាភ្ញី ទៀនធូប និងគ្រឿងក្រអូបជាដើម, ក្នុងសម័យទំនើបនេះ មានការតាក់តែងដោយភ្លើងពណ៌រំលេចរស្មីច្រើនប្រភេទនៅត្រង់បុស្បុកនោះផង ។

ជាដំបូង លោកអាចារ្យដឹកនាំពុទ្ធបរិស័ទដែលអង្គុយត្រៀបត្រាក្នុងរោងបុណ្យ សូត្រធម៌នមស្ការសង្ខេប ហើយប្រកាសពិធីកិច្ចនីមួយៗដែលត្រូវធ្វើ ។ នៅអមសងខាងបុស្បុក មានបុរសឈរកាន់គង និងខ្លះទៀតកាន់ខ្លុយ ឬស្នែង, មានស្រីកញ្ញា ៤ ឬ ៥ នាក់ស្លៀកពាក់ស្អាត ៗ ដូចគ្នាអង្គុយកាន់ជើងពានផ្កា ឯខាងក្រៅរោង មានបុរសចាំអុជកាំជ្រួច, គង ខ្លុយ ឬស្នែង និងកាំជ្រួច ត្រូវចាប់ផ្តើមបន្លឺឡើងព្រមគ្នា ក្នុងពេលដែលលោកអាចារ្យដឹកនាំស្រែកជ័យឃោសន៍និងបូជាផ្កាម្តង ៗ ។

ក្នុងពិធីនេះដែរ មានព្រះសង្ឃគង់នៅលើអាសនៈផ្នែកម្ខាងដើម្បីត្រៀមសូត្រធម៌មាន ជយបរិត្តគាថា និង ពុទ្ធជយមង្គលគាថា ជាដើមក្នុងពេលលោកអាចារ្យធ្វើចប់កម្មវិធីមួយវគ្គៗ ។

តាមសៀវភៅ " **ពុទ្ធាភិសេក** " របស់សម្ដេចសង្ឃរាជ **ជួន ណាត** បានពន្យល់ថា " ការស្រោចស្រព ឬជជុះរលាស់ ប្រោះព្រំនូវសុគន្ធវារីថ្វាយព្រះពុទ្ធរូបដែលទើបសាងថ្មី ហៅថា ពុទ្ធាភិសេក "។ លោកបន្ថែមថា ពិធីនេះជាប្រពៃណី ដែលពុទ្ធបរិស័ទបានធ្វើអស់កាលយូរអង្វែងហើយជាប់មានដរាបដល់សម័យយើងសព្វថ្ងៃ ។ បណ្ឌិតអ្នកប្រាជ្ញពុទ្ធ-សាសនិកទាំងឡាយ មានព្រះនាគសេនមហាថេរជាដើម បានធ្វើតាមលំនាំរឿងដែលព្រះមហាបុរស សិទ្ធត្ថសក្យមុនីគោតម ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិ បានដល់នូវឋានៈជាព្រះអរហន្តសម្មាសម្ពុទ្ធប្រាកដឡើង នៅពេលខាងចុងបច្ឆិមយាម នៃរាត្រីពេញបូណ៌មីខែពិសាខនោះ ។ គ្រាន់តែព្រះអង្គបានផ្ចាញ់មារហើយ និងបានត្រាស់ជាព្រះសម្ពុទ្ធភ្លាម ក៏កើតមានអព្ភូតហេតុជាមហស្ចារ្យ, ទេវតា ឥន្ទ្រព្រហ្មទាំងឡាយនិម្មិតខ្លួនតូចៗល្អិត ៗ មកប្រជ្រៀតគ្នាណែនណាន់តាន់តាប់បន្លឺវាចាអឺងអាប់ថ្វាយពរថ្វាយជ័យចំពោះព្រះអង្គថា "ព្រះពុទ្ធមានសិរីទ្រង់ឈ្នះមារហើយ មារមានចិត្តបាបចាញ់ព្រះអង្គហើយ " ។ មិនតែប៉ុណ្ណោះ ពួកទេវតាឥន្ទ្រព្រហ្មទាំងនោះថែមទាំងបានបាចសាចសុគន្ធបុប្ផាទិព្វ ប្រោះព្រំសុគន្ធវារីទិព្វផង រីឯពួកគន្ធព្វទេវតាប្រគំតន្ត្រីទិព្វ

ថ្វាយចំពោះព្រះអង្គផងដែរ ដោយអំណរដ៏ក្រៃលែង, ព្រោះហេតុនោះ ឯងបានជាពិធីនេះឈ្មោះថា ពុទ្ធាភិសេក ។ ពិធីនេះចែកជា៣បែបគឺ បែបពិស្តារ បែបមធ្យម និងបែបសង្ខេប អាស្រ័យទៅលើពេលវេលា បុរាណគេធ្វើនៅថ្ងៃ ១៥ កើតខែពិសាខ តាំងពីព្រលប់រហូតទាល់ភ្លឺ គេ បញ្ចប់ពិធីនេះនៅពេលព្រឹកថ្ងៃ ១ រោច ។ ពុទ្ធសាសនិកជនបរទេស ខ្លះធ្វើពិធីនេះតាំងពីថ្ងៃទី ១៤ កើត ដោយមានចម្អិនមធុបាយាសថ្វាយ ចំពោះព្រះពុទ្ធរូបអង្គថ្មីផង ដើម្បីឲ្យត្រូវតាមដំណើររឿងនាងសុជាតា ថ្វាយមធុបាយាសចំពោះព្រះសិទ្ធត្ថពោធិសត្វក្នុងឧរុវេលាប្រទេស ។

ក្នុងសៀវភៅដដែលនេះបានប្រាប់ពីរបៀបធ្វើតាមប្រពៃណីជា ទម្លាប់ក្នុងប្រទេសកម្ពុជាយើងបែបមធ្យមមានរបៀបជា ៩ សង្កាត់គឺ ៖

១. រៀបគ្រឿងសក្ការបូជាមានផ្កាស្រស់ ៗ និងទៀនធូបជាដើម ថ្វាយព្រះពុទ្ធរូបអង្គថ្មី ។

២. និមន្តព្រះសង្ឃចម្រើនព្រះបរិត្ត ។

៣. និមន្តធម្មកថិកមួយអង្គសម្តែងរឿងបឋមត្រាស់ ។

៤. និមន្តព្រះភិក្ខុមួយឬពីរអង្គសូត្របាលីពុទ្ធាភិសេក ។

៥. សូត្របទធម្មប្បដិយោគ (ធ្លាប់ហៅថា ធមិយ៉ោក) ។

៦. សូត្របទផ្ចាញ់មារ ។

៧. និមន្តព្រះសង្ឃសូត្របាលីគាថា ពាហុំ, មហាការុណិកោ, តេ អត្ថលទ្ធា, ភវតុ សព្វមង្គលំ ។

៨. ពុទ្ធបរិស័ទបាចសាចផ្កាស្រស់ៗ បូជាគ្រឿងក្រអូប ឬរលាស់សុគន្ធវារីថ្វាយព្រះពុទ្ធរូបអង្គថ្មី ។

៩. ពុទ្ធបរិស័ទសូត្រធម៌នមស្ការព្រះរតនត្រ័យ និង ធម៌ឧទ្ទិសបុណ្យកុសលតាមទម្លាប់ ជាកិច្ចបញ្ចប់ ។

ចំណែកក្នុងសៀវភៅ "ប្រវត្តិព្រះបរមសារីរិកធាតុ" របស់លោកគ្រូធម្មានន្ទ **វ៉ាន់-ចាន់សារ៉េន** ប្រាប់ថា " ប្រពៃណីធ្វើពុទ្ធាភិសេកនេះមិនមែនមានតាំងពីសម័យពុទ្ធកាលនោះទេ គឺវាត្រូវបានបង្កើតឡើងក្នុងសម័យខាងក្រោយ រវាងព.ស. ២១២២ ( គ.ស. ១៥៧៩ ) ក្នុងពេលដែលមានប្រពៃណីបូជាផ្កាយនព្វគ្រោះ ត្រង់ក្រុងធៀងហ្មៃ ។ ក្នុងសម័យនោះ ព្រះចៅគ្រប់គ្រងនគរ និងព្រះសង្ឃបានប្រឹក្សាគ្នា ធ្វើពិធីបូជាព្រះពុទ្ធ ៩ អង្គដើម្បីផ្លាស់ប្តូរប្រពៃណីបូជាផ្កាយនព្វគ្រោះនោះ ។

ក្នុងការបូជាផ្កាយនព្វគ្រោះដូចពោលមកនេះ ព្រះសង្ឃធ្វើពុទ្ធាភិសេកដោយប្រពន្ធចងក្រងនិងស្វាធ្យាយមានពាក្យបាលីថា អនេកជាតិសំសារំ ជាដើម ។ ក្រោយពីនោះ សូម្បីការកសាងព្រះចេតិយនិងព្រះពុទ្ធរូបថ្មី ក៏គេនិមន្តព្រះសង្ឃធ្វើពុទ្ធាភិសេកនេះដែរ រហូតក្លាយជាប្រពៃណីដរាបដល់យើងសព្វថ្ងៃនេះ ។ ក៏ប៉ុន្តែជាអកុសល ប្រពៃណីធ្វើពុទ្ធាភិសេក ក្នុងប្រទេសខ្មែរយើងដែលនិយមធ្វើតៗគ្នាមកក៏ល្អៀងក្លាយទៅជារបៀបព្រហ្មញ្ញសាសនាខ្លះ ដូចមានការសេពមន្តអាគមគាថាយ័ន្តខ្លះក៏មាន ធ្វើឲ្យច្របូកច្របល់រកយល់ផ្លូវត្រូវមិនឃើញ, រីឯ

កន្លែងខ្លះទៀត គេយកខ្សែអំបោះចងប្រទាក់ពីព្រះពុទ្ធរូបចាស់ តភ្ជាប់ព្រះពុទ្ធរូបថ្មី មានអាចារ្យរុំអំបោះជុំវិញព្រះពុទ្ធរូប ដោយសេពអាគម-អួមអាមជ្រេងៗផងទៅតាមទម្លាប់ពីមុនមក ដូច្នេះជាដើម ។"

ដូច្នេះក្នុងទីនេះ ដើម្បីឲ្យពុទ្ធបរិស័ទជ្រាបកាន់តែច្បាស់នូវហេតុដែលទាក់ទងនឹងពិធីពុទ្ធាភិសេក ខ្ញុំសូមពណ៌នាតាមដំណើររឿងដោយសង្ខេបដូចខាងក្រោម ដែលមានសេចក្ដីដំណាលថា ៖

## សុជាតាគថា

ពោធិសត្តោ រតនបល្លង្កំ ឥស្វា បន្ទាប់ពីព្រះពោធិសត្វបានទទួលមធុបាយាស អំពីនាងសុជាតាជាធីតានៃសេនកុដុម្ពិក ក្នុងឧរុវេលាប្រទេសនាថ្ងៃ ១៤ កើតខែពិសាខហើយ ស្ដេចទ្រង់យាងត្ដោះទៅរតនបល្ល័ង្ក ត្រង់មណ្ឌលពោធិព្រឹក្ស និងឡើងគង់ បែរព្រះបិដ្ឋិទៅរកដើមពោធិ៍ បែរព្រះភក្ត្រទៅទិសបូព៌ា ដោយតាំងព្រះទ័យយ៉ាងមុតមាំថា "កាមំ តចោ នហារូ ច អដ្ឋិ ច អវសិស្សតុ សព្វំបិ ហិទំ សរីរេ មំសលោហិតំ ឧបសុស្សតុ ឥនេវ សម្មាសម្ពោធិំ អប្បត្វា ឥមំ បល្លង្កំ ន ភិន្ទិស្សាមិ ។ ប្រែថា ស្បែក សរសៃ ឆ្អឹង សាច់ និងឈាម នៃអាត្មាអញទាំងអស់ ក្នុងសរីរៈនេះ ចូរឲ្យរីងស្ងួតទៅ, បើមិនបានដល់នូវសម្មាសម្ពោធិញ្ញាណ ក្នុងទីនេះទេ អាត្មាអញនឹងមិនទម្លាយនូវភ្នែននេះឡើយ "។

# មារវិជយកថា

តស្មឹ សមយេ មារោ ទេវបុត្តោ សម័យនោះឯងទេវបុត្ត-មារមានគំនិតអាក្រក់ មិនប្រាថ្នាឲ្យព្រះសិទ្ធត្ថ កន្លងវិស័យរបស់ខ្លួនបាន ក៏នាំពួកពលមារសេនាដ៏ច្រើន មកផ្ចាញ់ផ្ចាលព្រះអង្គ ត្រង់មណ្ឌលពោធិបល្ល័ង្ក គឺពីខាងមុខកម្រាស់ ១២ យោជន៍, ពីខាងឆ្វេងនិងខាងស្តាំ ១២ យោជន៍ដូចគ្នា, ពីខាងក្រោយច្រើនណែនណាន់តាន់តាប់ រហូតដល់កណ្តាប់ចក្រវាល ខាងលើកម្រាស់ ៩ យោជន៍, បានញុំាងសំឡេងសម្លុតគំរាម ឲ្យលាន់ឮខ្ទរខ្ទាយទៅចម្ងាយ ១ សែនយោជន៍ដោយជុំវិញ បីដូចសន្ទឹកកក្រើកផែនដី ។ មារោ ទេវបុត្តោ បញ្ញាសាធិកយោជនសតុព្វេធំ ក្នុងគ្រានោះ ទេវបុត្តមារឡើងជិះលើដំរីគិរីមេខលាខ្ពស់ ១៥០ យោជន៍ និម្មិតដៃ ១ ពាន់ កាន់គ្រឿងអាវុធមានប្រការផ្សេង ៗ រីឯសេនាមារសោត ក៏និម្មិតកាយប្លែក ៗ មានជាយក្សខ្លះ សត្វសាហាវខ្លះ បក្សីខ្លះ ហោះទៅកាន់ពោធិមណ្ឌលរាល់ៗគ្នា ។ មារេ ពោធិមណ្ឌលំ អសម្បត្តេ នាកាលមារនិងពួកពល មិនទាន់ចូលដល់ពោធិមណ្ឌលនៅឡើយ ទេវតាទាំងឡាយក្នុង ១ មុឺនចក្រវាល មានសក្កទេវរាជ ព្រហ្មនិងនាគជាដើម ដែលមកជុំគ្នាចោមរោមព្រះពោធិសត្វនោះ គ្រាន់តែបានឮសន្ទឹកគឹកកងនៃពួកពលមារលើកមក ក៏រត់ខ្ចាត់ខ្ចាយទៅកាន់និវេសន៍របស់ខ្លួនអស់ នៅតែព្រះសិទ្ធត្ថមួយអង្គឯង ប៉ុន្តែព្រះអង្គទ្រង់មិនខ្លាចញញើតពួកមារនោះសូម្បីបន្តិចឡើយ ។

អថ មារោ អត្តនោ បរិសំ អាហ លំដាប់នោះ មារាធិរាជ ក៏ស្រែកប្រាប់បរិស័ទនៃខ្លួនថា “ម្នាលគ្នាយើង បុរសស្មើនឹងសិទ្ធត្ថនេះ មិនមានទេ យើងមិនអាចធ្វើសង្គ្រាមក្នុងទីចំពោះមុខព្រះអង្គបានឡើយ យើងចូលទៅខាងឆ្វេង ខាងស្តាំនិងខាងក្រោយប៉ុណ្ណោះ ” ។ ឯមហា - បុរសទ្រង់ទតទៅឥតឃើញមានអ្នកណាសោះ ក្រៅតែពីពួកមារដ៏ច្រើនត្រៀបត្រា ទើបទ្រង់ព្រះចិន្តាថា មាតាក្តីបិតាក្តី ញាតិសន្តាននៃអញក្តីឬអ្នកឯណានីមួយក្តី មិនមានឡើយក្នុងទីនេះ រួចក៏ទ្រង់រំពឹងដល់បារមីទាំង ១០ ដែលព្រះអង្គបានសន្សំអស់កាលដ៏យូរ ទុកដូចជាបរិវារ ។ លំដាប់នោះពួកមារមានចិត្តបាប ក៏បណ្តាលជាគ្រឿងប្រហារ ៩ យ៉ាងដើម្បីបៀតបៀនព្រះអង្គគឺ ខ្យល់ព្យុះ, ភ្លៀងធំ ភ្លៀងដុំថ្ម ភ្លៀងគ្រឿងសស្ត្រា ភ្លៀងរងើកភ្លើង ភ្លៀងផេះក្តៅ ភ្លៀងដីខ្សាច់ ភ្លៀងភក់ និង ងងឹតផ្សេងអំពូ គ្រប់ទិសទាំង ៤ ប៉ុន្តែគ្រឿងប្រហារទាំងនោះ មិនអាចបៀតបៀនព្រះមហាសត្វបានឡើយ ត្រលប់ក្លាយទៅជាគ្រឿងបូជាព្រះអង្គវិញ ។

ឯវំ មារោ ឥមាហិ នវហិ វាតវស្សាទីហិ ឯស្តេចមារកាលមិនអាចឲ្យព្រះសិទ្ធត្ថវិនាសដោយហេតុ ៩ ប្រការ មានខ្យល់និងភ្លៀងជាដើមបាន ទើបបង្គាប់មារសេនាឲ្យចូលទៅចាប់សម្លាប់ ឬក៏បណ្តេញព្រះអង្គឲ្យរត់ចេញទៅ, ចំណែកក្រុងមារសោត ក៏ជិះដំរីមានដៃ១ពាន់ប្រដាប់ដោយអាវុធបរចូលទៅជិតហើយពោលថា “នៃសិទ្ធត្ថចូរអ្នកក្រោកចេញចាករតនបល្ល័ង្កនេះៗ មិនត្រូវបានអ្នកទេ ត្រូវបាន

មកយើងទេតើ ” ព្រះពោធិសត្វក៏ពោលតបថា “ម្នាលមារអើយ បារមីទាំង ៣០ ប្រការ មហាបរិច្ចាគ ៥ និងចរិយា ៣ អ្នកឯងមិនបានបំពេញទេ, បល្ល័ង្កនេះមិនមែនកើតសម្រាប់អ្នកទេ បល្ល័ង្កនេះកើតឡើងដោយបុណ្យបារមីរបស់យើងទេតើ ” ។

មារោ ចាបិមា រសិតមានសោ វិមារមានចិត្តបាបបានឮហើយ ក៏រឹតតែក្រេវក្រោធឡើង រួចចាប់យកចក្រាវុធចោលតម្រង់ទៅរកព្រះមហាសត្វ ឯចក្រាវុធក៏ក្លាយជាពិតានឋិតនៅខាងលើព្រះអង្គ ។ ចំណែកមារបរិស័ទក៏លើកកំពូលភ្នំធំ ៗ គ្រវែងសំដៅព្រះមហាឫសី ឯកំពូលភ្នំសោតក៏ក្លាយទៅជាមាលាបូជាវិញ ។ ព្រះអង្គទ្រង់ព្រះចិន្តាថា “បល្ល័ង្កដែលកើតដល់ព្រះពោធិសត្វទាំងឡាយ ក្នុងថ្ងៃជាទីត្រាស់ដឹងបានកើតឡើងដល់អាត្មាអញក្នុងថ្ងៃនេះ ” ។ តតោ មហាបុរិសោលំដាប់នោះមហាបុរសពិចារណាដល់ទានបារមី ដែលព្រះអង្គបានឲ្យដំរីស ក្នុងកាលសោយជាតិជាព្រះវេស្សន្តរ រំពេចនោះគិរីមេខលហត្ថីពុំអាចទប់អាត្មាបាន ក៏ទន់ជង្គង់លុតចុះលើមហាប្រឹថពី, ឯមារសោតក៏លើកដៃទាំងពាន់ដាក់លើត្បូង ពោលសរសើរព្រះពោធិសត្វថា ៖

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**
**សទេវកស្មឹ លោកស្មឹ នត្ថិ តេ បដិបុគ្គលោ**
**តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ តុវំ**
**អនុសយេ ឆិន្នោ តិណ្ណោ តារេសិ មំ បជំ ។**

បពិត្របុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្របុរសដ៏ឧត្តម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ក្នុងលោកនេះព្រមទាំងទេវលោក មិនមានបុគ្គលណាប្រៀបផ្ទឹមនឹងព្រះអង្គបានឡើយ ព្រះអង្គជាព្រះពុទ្ធ ព្រះអង្គជាសាស្តាចារ្យ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់គ្របសង្កត់នូវពួកមារ ព្រះអង្គជាអ្នកកាត់ផ្តាច់នូវអនុស័យកិលេស ទ្រង់ឆ្លងផុតចាកសង្សារហើយ សូមទ្រង់ចម្លងនូវសត្វជាខ្ញុំផងចុះ ។

## ប្រែពាក្យកាព្យ

បពិត្រព្រះម្ចាស់ថ្លៃ មានជាញជ័យដ៏អស្ចារ្យ
ជាបុរសខ្ពស់ថ្លៃថ្លា មនុស្សទេវតាប្រៀបពុំបាន ។
ព្រះអង្គជាព្រះពុទ្ធ គុណវិសុទ្ធផុតភពឋាន
ត្រាស់ដឹងពុទ្ធញាណ យល់សព្វគ្រប់គ្មានចន្លោះ ។
ជាសាស្តាចារ្យឯក គុណអនេកអនន្តខ្ពស់
ដឹកនាំសត្វទាំងអស់ ឆ្លងដល់កោះត្រើយសុខា ។
ទ្រង់ជាមហាមុនី ដ៏ជាទីត្រេកជ្រះថ្លា
ទាំងមនុស្សព្រហ្មទេវតា នាគគ្រុឌមារស្ម័គ្រគោរព ។
ទ្រង់គ្របសង្កត់មារ ដែលរាំងរាបំណងសព្វ
ឲ្យមារវិលត្រលប់ ក្រាបគោរពចាញ់ចេស្តា ។
ទ្រង់កាត់នូវកិលេស ល្អិតវិសេសគ្រប់ប្រការ

ឆ្លងចាកសង្សារា ផុតទុក្ខាដល់និព្វាន ។
បពិត្រព្រះមហេសី សូមអភ័យជួយប្រោសប្រាណ
ឲ្យសត្វខ្ញុំនេះបាន ដល់ត្រើយត្រាណនិព្វានផង ។

(ដោយឧបាសក ជួន-ម៉ែន ខេត្តកំពង់ឆ្នាំង)

## ជយឃោសនកថា

លុះមារពោលនមស្ការរួចហើយ ក៏ហោះទៅកាន់ពិភពរបស់ខ្លួនវិញ ចំណែកខាងពលមារក៏រត់បែកខ្ញែកទៅកាន់ទិសានុទិសរៀងៗខ្លួន។ លំដាប់នោះ ទេវតាទាំងឡាយកាលបានឃើញមារបរាជ័យចាលចាញ់ព្រះពោធិសត្វ រត់ខ្ចាត់ខ្ចាយអស់ហើយ ក៏ប្រឹក្សាគ្នានិងប្រកាសប្រាប់ដល់បក្សពួករបស់ខ្លួនៗ ដើម្បីនឹងធ្វើជយបូជាថ្វាយចំពោះព្រះអង្គ, រីឯពួកនាគ ពួកគ្រុឌ និងពួកព្រហ្ម ក៏ប្រកាសប្រាប់ដល់បរិស័ទរបស់ខ្លួន ៗ ដូចគ្នា។ ពួកជនទាំងនោះសុទ្ធតែមានដៃកាន់គ្រឿងក្រអូបនិងផ្កាជាដើម នាំគ្នាចូលទៅកាន់ពោធិបល្ល័ង្ក មានចិត្តត្រេកអរ ស្រែកឃោសនាថ្វាយជ័យចំពោះព្រះសិទ្ធត្ថពោធិសត្វគ្រប់ៗគ្នាដូច្នេះថា ៖

១. “ ជយោ ហិ ពុទ្ធស្ស សិរិមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ ”
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា នាគគណា មហេសិនោ ។

*ប្រែ : ក្នុងគ្រានោះ ពួកនាគមានចិត្តរីករាយ បានចូលមកជិតពោធិមណ្ឌល ស្រែកថ្វាយជ័យ ចំពោះព្រះមហាសត្វ ជាមហាឫសីថា “ ជ័យជម្នះនេះ ជាជ័យជម្នះ របស់ព្រះសម្ពុទ្ធដ៏មានសិរី រីឯបរាជ័យ ជារបស់នៃមារ មារមានចិត្តបាប ចាញ់ព្រះអង្គហើយ ” ។*

**ប្រែមួយបែបទៀតថា :** *“ ព្រះពុទ្ធដ៏មានសិរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាប ចុះចាញ់ព្រះអង្គហើយ ” ។*

**២. “ ជយោ ហិ ពុទ្ធស្ស សិរិមតោ អយំ**
**មារស្ស ច បាបិមតោ បរាជយោ ”**
**ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា**
**សុបណ្ណសង្ឃាបិ ជយំ មហេសិនោ ។**

*ក្នុងគ្រានោះ ពួកគ្រុឌមានចិត្តរីករាយ ។ល។ (ប្រែដូចមុន)*

**៣. “ ជយោ ហិ ពុទ្ធស្ស សិរិមតោ អយំ**
**មារស្ស ច បាបិមតោ បរាជយោ ”**
**ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា**
**ជយំ តទា ទេវគណា មហេសិនោ ។**

*ក្នុងគ្រានោះ ពួកទេវតាមានចិត្តរីករាយ ។ល។ (ប្រែដូចមុន)*

**៤. “ ជយោ ហិ ពុទ្ធស្ស សិរិមតោ អយំ**
**មារស្ស ច បាបិមតោ បរាជយោ ”**
**ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា**
**ជយំ តទា ព្រហ្មគណាបិ តាទិនោ ។**

ក្នុងគ្រានោះ ពួកព្រហ្មមានចិត្តរីករាយ។ល។ ស្រែកថ្វាយជ័យចំពោះព្រះមហាសត្វ ជាគាថាទិបុគ្គលដូច្នេះថា (ប្រែដូចមុន)

បញ្ជាក់ : ក្នុងពេលពោលចប់ធម៌ ១ សង្កាត់ ៗ បរិស័ទគប្បីធ្វើការបូជា គ្រឿងក្រអូប បាចផ្កា និងអុជកាំជ្រួចជាដើមឡើង ។

**ប្រែពាក្យកាព្យ**

ជ័យជម្នះនេះ យ៉ាងធំវិសេស នៃព្រះពុទ្ធអង្គ
ដ៏មានសិរី រស្មីផូរផង់ ទ្រង់កម្ចាត់បង់
នូវមារទាំងអស់ ។
មារមានចិត្តបាប ចាញ់ព្រះដរាប មិនដែលឈ្នះសោះ
ព្រះអង្គឈ្នះមារ ដោយញាណខ្ពង់ខ្ពស់ ឧត្តមកិត្តិយស
ជាព្រះពុទ្ធហោង ។

**(ដោយឧបាសក ជួន-ម៉ែន)**




ព្រះអង្គផ្ចាញ់មារ

# អភិសម្ពោធិកថា

**មហាបុរិសោ សុរិយេ អនត្ថង្គតេ ឯវំ មារពលំ វិធំ-សេត្វា** បន្ទាប់ពីព្រះមហាបុរសកម្ចាត់នូវពួកមាររួចហើយ នាកាលព្រះអាទិត្យពុំទាន់អស្តង្គតនៅឡើយ ត្រួយស្លឹកពោធិព្រឹក្សមានពណ៌ប្រាកដដូចកែវប្រពាល ជ្រុះធ្លាក់ចុះមកលើចីវរបូជាព្រះអង្គ ។ លុះដល់បឋម-យាមនៃរាត្រី ពេញបូណ៌មី ខែពិសាខ ព្រះអង្គទ្រង់ជម្រះចិត្តឲ្យផូរផង់តាំងនៅល្អបរិសុទ្ធប្រាសចាកនីវរណធម៌ ឥតមានទីទួលគឺកិលេស មានចិត្តគួរដល់ភាវនាធម៌ ដោយអំណាចឈានទាំង ៤ ដូច្នេះហើយ ព្រះមហាបុរសក៏បង្អោនព្រះទ័យដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺញាណអាចរឭកនូវខន្ធដែលធ្លាប់អាស្រ័យហើយក្នុងកាលមុន គឺតាំងពី១ ជាតិរហូតច្រើនសំវដ្តវិវដ្តកប្បខ្ទះ ។ **មជ្ឈិមយាមសមនន្តរេ** លុះដល់មជ្ឈិមយាម ទ្រង់ជម្រះនូវទិព្វចក្ខុ ដើម្បីចុតូបបាតញ្ញាណ រមែងឃើញនូវពួកសត្វដែលច្យុតនិងកើត ថោកទាបនិងឧត្តម ទៅតាមយថាកម្ម ។ **តទនន្តរំ ញាណំ ឱតារេត្វា** លំដាប់អំពីមជ្ឈិមយាមនោះមក ព្រះអង្គទ្រង់ញ៉ាំងញាណឲ្យចុះកាន់បច្ចយាការៈ គឺបដិច្ចសមុប្បាទធម៌ជាអនុ-លោមបដិលោម ដើម្បីស្រាវជ្រាវរាវរកប្រភព នៃសេចក្តីទុក្ខពោលគឺអវិជ្ជា និងដំណើររលត់ទៅនៃទុក្ខ គឺការរលត់ទៅនូវអវិជ្ជា ដែលមានបទបាលីថា **អវិជ្ជា បច្ចយា សង្ខារា** ជាដើម ។[១] កាលស្តេចកំពុង

---

១-ត្រង់វគ្គនេះ គួរសូត្របដិច្ចសមុប្បាទធម៌ មួយសង្កាត់សិន ។

ពិចារណា នូវបច្ចយាការៈ ដែលប្រកបដោយអង្គ ១២ ដូច្នេះហើយ ធម៌ទាំងឡាយនេះគឺ ចក្ខុ ញាណ បញ្ញា វិជ្ជា ពន្លឺ ក៏កើតមានឡើងដល់មហាបុរសដែលមិនធ្លាប់បានឮបានស្តាប់ កាលពីមុនក្នុងទីនោះឯង ឯលោកធាតុទាំងមួយម៉ឺន ក៏រញ្ជួយកម្រើកអស់វារៈ ១២ ដង ដរាបដល់ទឹកទ្រផែនដីជាទីបំផុត ។ ព្រះមហាមុនីទ្រង់ប្រកបដោយសិរីសោភគ្គសម្បត្តិដ៏រុងរឿងក្រៃពេក ព្រះអង្គបានត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិធម៌ ក្នុងវេលារះឡើងនៃអរុណថ្ងៃ ១ រោច ។

តស្មិំ សព្វញ្ញុតំ បត្តេ នាកាលព្រះមហាសត្វ បានដល់នូវភាវៈជាសព្វញ្ញុពុទ្ធ ប្រសើរផុតជាងសត្វក្នុងត្រៃភពហើយ លោកធាតុទាំងមួយម៉ឺន ដ៏ប្រដាប់ដោយគ្រឿងលម្អគឺទង់ជ័យ ដែលពួកទេពទាំង - ឡាយលើកឡើង ពេញតទល់គ្នាក្នុងចតុទិសាភាគ ដរាបដល់ចក្រវាលដាលតាំងពីផែនដីដល់ព្រហ្មលោកនាយ ។ រុក្ខសាខាលតាជាតិ ក៏មានផ្ការីកស្គុសស្គាយសំយុងចុះ, ចំណែកបទុមបុប្ផាក៏ចេញផ្កាចម្រុះពណ៌ឯនភាកាស រីឯខ្លះរីកដុះទម្លុះផែនសិលាមហាប្រឹថពី, លោកធាតុទាំងមួយម៉ឺនសោត សុទ្ធសឹងដេរដាសដោយធជបដានិងផ្កាទាំងអស់ ។

ឯវំ ភគវា គ្រានោះ ព្រះវិជិតមារដែលពួកទេវតាបូជា ដោយគ្រឿងសក្ការៈគណនាត្រាប់មិនបានយ៉ាងនេះហើយ ទ្រង់ក៏សរសើរនូវជម្នះរបស់ព្រះអង្គដោយបន្លឺឧទានគាថា ដែលព្រះពុទ្ធគ្រប់ព្រះអង្គពុំដែលលះបង់ដូច្នេះថា ៖

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។**

*ប្រែ : កាលអាត្មាអញមិនទាន់បានជួបប្រទះ នូវពោធិញ្ញាណនៅឡើយ វង្វេងរកជាងផ្ទះគឺតណ្ហា អ្នកធ្វើនូវផ្ទះគឺអត្តភាព ហើយអន្ទោលទៅអស់សង្សារមានជាតិដ៏ច្រើន, ជាតិគឺការកើតរឿយ ៗ រមែងនាំមកនូវសេចក្តីទុក្ខ, នែជាងផ្ទះគឺតណ្ហា ! (ឥឡូវនេះ) យើងបានឃើញអ្នកច្បាស់ហើយ អ្នកឯងនឹងធ្វើនូវផ្ទះគឺអត្តភាព(នេះ)ឲ្យយើងទៀតមិនបានឡើយ ។ ឆ្អឹងជំនីរគឺកិលេសទាំងអស់របស់អ្នកឯង យើងបានបំបាក់ចោលហើយ ទាំងកំពូលនៃផ្ទះគឺអវិជ្ជារបស់អ្នកសោត យើងបានបំបាក់ចោលអស់ហើយដែរ ។ ចិត្តរបស់យើង បានដល់នូវនិព្វានដែលឥតសង្ខារហើយ យើងបាននូវអរហត្ត គឺការអស់តណ្ហាទាំងឡាយហើយ ។*

***(ពុទ្ធប្បវត្តិ អវិទូរេនិទាន)***

## ប្រែពាក្យកាព្យ

*កាលពីអង្គអញតថាគត អន្ទោលក្នុងវាលវដ្តសង្សារ*
*ច្រើនអស់អសង្ខេយ្យកោដិកប្បា តែងបានទុក្ខាវាល់ជាតិភព ។*
*ឥឡូវតណ្ហាគឺជាងផ្ទះ តថាគតយល់ច្បាស់ក្នុងចិត្តស៊ប់*

បានដឹងបានឃើញដោយសព្វគ្រប់ អ្នកឈប់សង់ផ្ទះទៀតបានហើយ
ធ្នឹមជំនីរនឹងដំបូលអ្នក ត្រូវអញបំបាក់ឥតសល់ឡើយ
ចិត្តតថាគតបានដល់ត្រើយ ឥតតណ្ហាឡើយគឺនិព្វាន ។

*(ខ្មែរអាត់ទី១០ លោកគ្រូ ហ្គោតនហ្គា)*

## រតននមក្ការគាថា

លុះពោលដំណើរហេតុជាខាងដើមរួចហើយ លោកអាចារ្យចាប់ផ្ដើមសូត្រធម៌នេះឡើង នៅពេលចប់ ១ សង្កាត់ ៗ បរិស័ទគប្បីធ្វើការបូជាថ្វាយគ្រឿងសក្ការៈដូចមុន ។

**យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ**
**តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ ។**

មនុស្សសត្វផងនានា បាននាំគ្នាមកមូលផង
ក្នុងនាទីនេះហោង ទាំងទេវតានាដែនដី ។
ទោះទាំងលើអាកាស សូមរួតរះមកឃ្មាតខ្មី
តម្រង់ផ្ចង់ស្មារតី មកស្វាគមន៍រួបរួមផង ។
យើងខ្ញុំទាំងអស់គ្នា សូមនមស្ការសច្ចាជ្រះ
គ្រប់អង្គព្រះពុទ្ធផង ដែលមានមកពីបុរាណ ។
ព្រមដោយមហាករុណា ទ្រង់ទេសនាទុកទូន្មាន
ទេវតាមនុស្សក្រេមក្សាន្ត បានគោរពធ្វើបូជា ។

សុវត្ថិមង្គល គឺមគ្គផលសត្វប្រាថ្នា
ទាំងប្រាំបីប្រការ កើតចម្រើនដល់សត្វហោង ។

* អនុមោទនា អបអរសាទរនឹងព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់បានត្រាស់ដឹងហើយហ្ន៎!..... អស់លោកអ្ហឺយ! ។ បរិស័ទថា សាធុ សាធុ!!! (បាចផ្កា, ភ្លេងពិណពាទ្យរោទ៍, វាយគង, ផ្លុំស្នែង និងអុជកាំជ្រួច) ។

**យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ**
**តថាគតំ ទេវមនុស្សបូជិតំ ធម្មំ នមស្សាម សុវត្ថិ ហោតុ ។**

មនុស្សសត្វផងនានា បាននាំគ្នាមកមូលផង
ក្នុងនាទីនេះហោង ទាំងទេវតានាដែនដី ។
ទោះទាំងលើអាកាស សូមរូតរះមកឃ្មាតខ្មី
តម្រង់ផ្ចង់ស្មារតី មកស្វាគមន៍រួបរួមផង ។
យើងខ្ញុំទាំងអស់គ្នា សូមនមស្ការសច្ចាផ្សង
នូវគុណព្រះធម៌ផង ដែលជាធម៌ល្អវិសេស ។
មានមកពីបុរាណ ជាលំអានប្រហានកិលេស
ទេវតានិងមនុស្សត្រិះ- រិះរាប់អានធ្វើបូជា ។
សុវត្ថិមង្គល គឺមគ្គផលសត្វប្រាថ្នា
ទាំងប្រាំបីប្រការ កើតចម្រើនដល់សត្វហោង ។

* អនុមោទនា អបអរសាទរ ថ្វាយបង្គំព្រះធម៌កើតមានហើយហ្ន៎ !...........អស់លោកអ្ហឺយ! ។ បរិស័ទថា សាធុ សាធុ!!!

(បាចផ្កា, ភ្លេងពិណពាទ្យរោទ៍, វាយគង, ផ្លុំស្នែង និងអុជកាំជ្រួច) ។

**យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ**

**តថាគតំ ទេវមនុស្សបូជិតំ សង្ឃំ នមស្សាម សុវត្ថិ ហោតុ ។**

មនុស្សសត្វផងនានា បាននាំគ្នាមកមូលផង
ក្នុងនាទីនេះហោង ទាំងទេវតានាផែនដី ។
ទោះទាំងលើអាកាស សូមរូតរះមកឃ្មាតខ្មី
តម្រង់ផ្ចង់ស្មារតី មកស្វាគមន៍រួបរួមផង ។
យើងខ្ញុំទាំងអស់គ្នា សូមនមស្ការសច្ចាផ្សង
គ្រប់អង្គព្រះសង្ឃផង ដែលជាក្រុមអរិយសង្ឃ ។
មានមកពីបុរាណ ជាលំអានអ្នកស្រោចស្រង់
ទេវតានិងមនុស្សផ្ចង់ ធ្វើសក្ការៈបូជា ។
សុវត្ថិមង្គល គឺមគ្គផលសត្វប្រាថ្នា
ទាំងប្រាំបីប្រការ កើតចម្រើនដល់សត្វហោង ។

* អនុមោទនា អបអរសាទរ ថ្វាយបង្គំព្រះសង្ឃកើតមានហើយហ្ន៎!............អស់លោកអ្ហើយ! ។ បរិស័ទថា សាធុ សាធុ !!!

(បាចផ្កា, ភ្លេងពិណពាទ្យរោទ៍, វាយគង, ផ្លុំស្នែង និងអុជកាំជ្រួច) ។

*ព្រះគ្រូ ម៉ី-ជួន និងលោកគ្រូ កែ-យឿង (កំពង់ឆ្នាំង)*

**ប្រែកាព្យមួយបែបទៀតថា ៖**

# ព្រះពុទ្ធរតនៈ

វិញ្ញូកភូតឯណា ជាទេវតាគ្រប់ភពឋាន
ឋិតនៅទិព្វវិមាន និងឧទ្យានព្រៃព្រឹក្សា ។
នៅនាដែនប្រឹថពី ជលធីអាកាសា
ដែលមកជួបជុំគ្នា នៅក្នុងគ្រាជាមង្គល ។
យើងខ្ញុំសូមនមស្ការ ចិត្តជ្រះថ្លាជាកុសល
គោរពរម្លឹកដល់ ព្រះទសពលទ្រង់ឈ្នះមារ ។
ត្រាស់ជាសព្វញ្ញូ ទ្រង់ជាគ្រូមនុស្សទេវតា
មានគុណមហាករុណា ដល់សត្តាគ្រប់ៗប្រាណ ។
សូមសុខសន្តិភាព មានរៀងរាបសព្វៗឋាន
ដរាបដល់និព្វាន សមដូចចិត្តប្រាថ្នាហោង ។

# ព្រះធម្មរតនៈ

វិញ្ញូកភូតឯណា ជាទេវតាគ្រប់ភពឋាន
ឋិតនៅទិព្វវិមាន និងឧទ្យានព្រៃព្រឹក្សា ។
នៅនាដែនប្រឹថពី ជលធីអាកាសា
ដែលមកជួបជុំគ្នា នៅក្នុងគ្រាជាមង្គល ។
យើងខ្ញុំសូមនមស្ការ ចិត្តជ្រះថ្លាជាកុសល

គោរពរម្លឹកដល់ ធម៌និមលស្អាតថ្លៃថ្លា ។
ជាធម៌ស្ងប់កិលេស គ្មានឆាបឆេះរាគតណ្ហា
ញ៉ាំងសត្វក្នុងលោកា បានសុខាសួគ៌និព្វាន ។
សូមមានមហាប្បញ្ញា ភ្លឺជ្រះថ្លាបដិភាណ
ដរាបដល់និព្វាន សមដូចចិត្តប្រាថ្នាហោង ។

# ព្រះសង្ឃរតនៈ

វីឮកភូតឯណា ជាទេវតាគ្រប់ភពឋាន
ឋិតនៅទិព្វវិមាន និងឧទ្យានព្រៃព្រឹក្សា ។
នៅនាដែនប្រឹថពី ជលធីអាកាសា
ដែលមកជួបជុំគ្នា នៅក្នុងគ្រាជាមង្គល ។
យើងខ្ញុំសូមនមស្ការ ចិត្តជ្រះថ្លាជាកុសល
គោរពរម្លឹកដល់ សង្ឃនិមលល្អថ្លៃថ្លា ។
ជាបុត្រព្រះទសពល ស្រីមង្គលគ្រប់ប្រការ
ចំជាបុញ្ញក្ខេត្តា ជនត្រូវការសាងសុន្ទរ៍ទាន ។
សូមមានអរិយទ្រព្យ ប្រសើរគាប់ជាប់សន្ដាន
ដរាបដល់និព្វាន សមដូចចិត្តប្រាថ្នាហោង ។

*(សៀវភៅ ឧបាសក ជួន-ម៉េន)*

.............

### ប្រែកាព្យមួយបែបទៀត គឺ :

## ព្រះពុទ្ធរតនៈ

ពួកភូតឯណា ដែលជាទេវតា នៅលើផែនដី
ឬនៅឰដ៏ ឯនភាល័យ ក្នុងទីនេះក្ដី
សមាគមជ្រះថ្លា ។
យើងខ្ញុំទាំងឡាយ បង្គំឱនកាយ សំពះនមស្ការ
នូវព្រះសម្ពុទ្ធ ជាសាស្ដាចារ្យ ដែលមនុស្សទេវតា
គោរពបូជា ។
ព្រះអង្គត្រាស់ដឹង ទ្រង់ជាទីពឹង នៃសត្វនានា
សូមសុខសួស្ដី សិរីសោភា ដល់យើងគ្រប់គ្នា
ក្នុងគ្រានេះហោង ។

## ព្រះធម្មរតនៈ

ពួកភូតឯណា ដែលជាទេវតា នៅលើផែនដី
ឬនៅឰដ៏ ឯនភាល័យ ក្នុងទីនេះក្ដី
សមាគមជ្រះថ្លា ។
យើងខ្ញុំទាំងឡាយ បង្គំឱនកាយ សូត្របទនមស្ការ
នូវព្រះសទ្ធម្ម ឧត្តមថ្លៃថ្លា ដែលមនុស្សទេវតា
គោរពបូជា ។

ស្វាក្ខាតធម៌ រុងរឿងបវរ លម្អសាសនា
សូមសុខសួស្តី សិរីសោភា ដល់យើងគ្រប់គ្នា
ក្នុងគ្រានេះហោង ។

## ព្រះសង្ឃរតនៈ

ពួកភូតឯណា ដែលជាទេវតា នៅលើផែនដី
ឬនៅឰដ៏ ឯនភាល័យ ក្នុងទីនេះក្តី
សមាគមជ្រះថ្លា ។
យើងខ្ញុំទាំងឡាយ បង្អោនចិត្តកាយ បូជានមស្ការ
នូវសាវ័កសង្ឃ ផូរផង់សីលា ដែលមនុស្សទេវតា
គោរពបូជា ។
ព្រះសង្ឃឧត្តម ជាបុញ្ញក្ខេត្តចំ សត្វក្នុងលោកា
សូមសុខសួស្តី សិរីសោភា ដល់យើងគ្រប់គ្នា
ក្នុងគ្រានេះហោង ។

*(ប្រែកាព្យដោយ ភិក្ខុ គល់-សុភាព (១២-៦-២០១៩)*

<u>បញ្ជាក់បន្ថែម</u> : ពិធីកិច្ចបូជាគ្រឿងសក្ការៈមានបាចផ្កាជាដើម ត្រូវធ្វើជា៧សង្កាត់ នេះតាមដែលធ្លាប់ឃើញធ្វើកន្លងមកគឺ បាចផ្កា ៤ ដង ពេលពោលចប់ធម៌ **ជយោ ហិ** ... រួច និង ៣ ដងទៀត ក្នុងពេលពោលចប់ធម៌ **យានិធ ភូតានិ** ... , ជាសរុប ៧ ដង ដោយប្រការដូច្នេះ ។


ព្រះអង្គត្រាស់ដឹង

# បទុមថ្វាយផ្កា

បន្ទាប់ពីពោលពាក្យសរសើរគុណ និងបូជាថ្វាយគ្រឿងសក្ការៈផ្សេង ៗ ចំពោះព្រះរតនត្រ័យរួចហើយ គប្បីឲ្យបុរសឬស្ត្រីម្នាក់ សូត្របទ “ បទុមថ្វាយផ្កា ” ដូច្នេះថា :

| | |
|---|---|
| បទុមក្រពុំរីក មានចិត្ត- | ត្រេក កាច់មកថ្វាយ |
| បទុម ក្រពុំថ្វាយ | បង់កាច់កាយ កបកេសរ ។ |
| លុតលើក ទាំងទសករ | ប្រណម្យ ដោមដាក់ លើសិរសី |
| ខ្ញុំក្រាប ក្រោមព្រះបាទ | អភិវាទ វរវន្ទា ។ |
| ថ្វាត់ថ្វាយ ទៅព្រះស្រី | រតនត្រ័យ ស្រីកាឡា |
| រុងរឿង បល្ល័ង្កពេជ្រ | វិចិត្រស្រេចក្បាច់រចនា |
| ថ្វាត់ថ្វាយវរវន្ទា | សូមបានសុខនិព្វានហោង ។ |

# បាលីទេរគ្រឿងសក្ការៈ

**ឱកាស មយំ ភន្តេ ឥមានិ បទីបគន្ធមាលាទីនិ សក្ការានិ សជ្ជេត្វា ( រតនត្តយស្ស ) ពុទ្ធស្ស បូជេម សាធុ ភន្តេ ពុទ្ធោ ភគវា ឥមានិ សក្ការានិ បដិគ្គណ្ហាតុ មាតាបិតាទីនំ គុណវន្តានញ្ច កម្មាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ទុតិយម្បិ . . . ។ តតិយម្បិ . . . ។**

បពិត្រព្រះអង្គដ៏ចម្រើនអើ្ហយ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គទាំងឡាយមានសទ្ធាជ្រះថ្លា បានតាក់តែងហើយ នូវគ្រឿងសក្ការៈទាំងឡាយ មានទៀនធូប ផ្កាកម្រង និងគ្រឿងក្រអូបជាដើមនេះ មកតម្កល់ទុកក្នុងទីនេះ

ដើម្បីបូជាថ្វាយ ចំពោះព្រះដ៏មានព្រះភាគ, បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាទទួលយក នូវគ្រឿងសក្ការៈទាំងឡាយនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើមផង (ដល់ទេវតាទាំងឡាយផង ដល់ពួកញាតិទាំងឡាយផង ដល់សព្វសត្វទាំងអស់ផង) និងដល់ខ្ញុំព្រះអង្គទាំងឡាយផង អស់កាលជាអង្វែងទៅហោង អស់វារៈពីរដងផង ។ល។ អស់វារៈបីដងផង ។

## ប្រែពាក្យកាព្យ

យើងខ្ញុំថ្វាយបង្គំ ព្រះបរមសាស្តាចារ្យ
ព្រះអង្គទ្រង់ឈ្នះមារ ប្រាំប្រការដោយជោគជ័យ ។
សម្រេចនូវត្រៃញាណ ឃើញនិព្វានមួយរាត្រី
ត្រាស់ដឹងដោយប្រពៃ នូវសច្ចៈបួនប្រការ ។
ជាព្រះពុទ្ធក្នុងលោក មានជ័យជោគមហាអស្ចារ្យ
ក្នុងមនុស្សនិងទេវតា រកអ្នកណាប្រៀបស្មើគ្មាន ។
យើងខ្ញុំសូមថ្វាត់ថ្វាយ ជីវិតកាយចិត្តវិញ្ញាណ
សទ្ធាជាប្រធាន ជឿញៀយញាណនៃព្រះអង្គ ។
ព្រមទាំងគ្រឿងសក្ការ ដែលរចនាយ៉ាងផ្ចិតផ្ចង់
បូជាចំពោះត្រង់ អង្គព្រះមុនិន្ទពិនពណ្ណរាយ ។
មានប្រទីបផ្កាលា ទៀនធូបផ្កាផងទាំងឡាយ

គ្រឿងអប់ក្រអូបសាយ    មាលាលាយចម្រុះផ្កា ។
ពិណពាទ្យគងប្រគំ    ស្នែងខ្លុយផ្គុំសាធុការ
ថ្វាយអង្គព្រះវិជិតមារ    ដូចកាលគ្រាទ្រង់បានត្រាស់ ។
នៅលើបល្ល័ង្កជ័យ    ក្រោមពោធិ៍ជ្រៃយ៉ាងប្រចក្ស
សត្វលោកត្រេកអរណាស់    ព្រះបានត្រាស់ភ្លឺច្បាស់ទៃង ។
ដោយគុណពុទ្ធបូជា    សូមឫទ្ធាខ្លាំងក្រៃលែង
បញ្ញាថ្លាចាំងចែង    មិនវង្វេងជុតទុក្ខា ។
សូមបានសុខសួស្តី    ជោគសិរីក្តីវឌ្ឍនា
តេជះព្រះឈ្នះមារ    ជួយរក្សាឲ្យសុខសាន្ត ។
សូមសព្វសត្វក្នុងលោក    ឃ្លាតទុក្ខសោកភ័យរំខាន
សម្បត្តិគុណកល្យាណ    សូមកើតមានសព្វៗកាល ។

*(ឧបាសក ជួន-ម៉េន)*

## សិរិឱន

### បទព្រហ្មគីតិ

សិរិឱនលំទោនកាយ    ហត្ថាថ្វាយបង្គំផ្ចង់
ចិត្តស្មោះចំពោះត្រង់    អង្គព្រះមុនិន្ទពិនលោកា ។
កាលទ្រង់គង់នៅឡើយ    ព្រះគុណអើយតែងមេត្តា
ប្រោសសត្វមនុស្សទេវតា    រាល់វេលាពុំដែលខាន ។

ឥឡូវព្រះពុទ្ធអង្គ នឹងទ្រាំគង់យូរពុំបាន
យាងចូលកាន់និព្វាន ខានទូន្មានយើងរាល់គ្នា ។
សាវ័កព្រះជាម្ចាស់ គង់ច្រើនណាស់នៅត្រៀបត្រា
បាត់តែអង្គសាស្តា ពីគ្រានោះលុះឥឡូវ ។
រឿងនេះសែនវិវេក គួរសង្វេគពេកណាស់កូវ
ព្រះរូបគង់ច្រផ្លូវ សត្វត្រូវពឹងយកនិស្ស័យ ។
ពេញបូណ៌មីវិសាខា ថ្ងៃនេះណាព្រះម្ចាស់ថ្លៃ
ប្រសូតចេញចាកផ្ទៃ និងក្សត្រថ្លៃចេញបព្វជ្ជា ។
បានត្រាស់ពោធិញ្ញាណ ចូលនិព្វានឋានសោភា
ពេញបូណ៌មីវិសាខា មានចរិតបួននោះឯង ។
កាលស្តេចនិព្វានទៅ សាវ័កនៅគិតកោតក្រែង
រៀបធ្វើគ្រឿងតាក់តែង រាល់វេលាតែរៀងរាប ។
មកដល់ឥឡូវនេះ យើងខ្ញុំនេះវន្ទាក្រាប
នឹកដល់ព្រះទ្រង់ភាព ជាបុញ្ញលាភទាន់សាសនា ។
ខ្ញុំបានគោរពហើយ ព្រះគុណអើយខ្ញុំប្រាថ្នា
ឲ្យទាន់ព្រះសិអារ្យ ត្រាស់ឯក្រោយដោយប្រពៃ ។
ពាក្យប៉ងបំណងណាត់ កុំបីភ្លាត់ឡើយម្ចាស់ថ្លៃ
សូមទាន់ព្រះមេត្តេយ្យ គ្រាន់អាស្រ័យទៅនិព្វាន ។

( បុរាណនិពន្ធ )

# ទាលីពុទ្ធាភិសេក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ពុទ្ធការកធម៌

១- ឥតិបិ ទានបារមិសម្បន្នោ សោ ភគវា
ឥតិបិ ទានឧបបារមិសម្បន្នោ សោ ភគវា
ឥតិបិ ទានបរមត្ថបារមិសម្បន្នោ សោ ភគវា
២- ឥតិបិ សីលបារមិសម្បន្នោ សោ ភគវា
ឥតិបិ សីលឧបបារមិសម្បន្នោ សោ ភគវា
ឥតិបិ សីលបរមត្ថបារមិសម្បន្នោ សោ ភគវា
៣- ឥតិបិ នេក្ខម្មបារមិសម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្មឧបបារមិសម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្មបរមត្ថបារមិសម្បន្នោ សោ ភគវា
៤- ឥតិបិ បញ្ញាបារមិសម្បន្នោ សោ ភគវា
ឥតិបិ បញ្ញាឧបបារមិសម្បន្នោ សោ ភគវា
ឥតិបិ បញ្ញាបរមត្ថបារមិសម្បន្នោ សោ ភគវា
៥- ឥតិបិ វីរិយបារមិសម្បន្នោ សោ ភគវា
ឥតិបិ វីរិយឧបបារមិសម្បន្នោ សោ ភគវា
ឥតិបិ វីរិយបរមត្ថបារមិសម្បន្នោ សោ ភគវា
៦- ឥតិបិ ខន្តិបារមិសម្បន្នោ សោ ភគវា
ឥតិបិ ខន្តិឧបបារមិសម្បន្នោ សោ ភគវា

ឥតិបិ ខន្តិបរមត្ថបារមីសម្បន្នោ សោ ភគវា

៧- ឥតិបិ សច្ចបារមីសម្បន្នោ សោ ភគវា

ឥតិបិ សច្ចឧបបារមីសម្បន្នោ សោ ភគវា

ឥតិបិ សច្ចបរមត្ថបារមីសម្បន្នោ សោ ភគវា

៨- ឥតិបិ អធិដ្ឋានបារមីសម្បន្នោ សោ ភគវា

ឥតិបិ អធិដ្ឋានឧបបារមីសម្បន្នោ សោ ភគវា

ឥតិបិ អធិដ្ឋានបរមត្ថបារមីសម្បន្នោ សោ ភគវា

៩- ឥតិបិ មេត្តាបារមីសម្បន្នោ សោ ភគវា

ឥតិបិ មេត្តាឧបបារមីសម្បន្នោ សោ ភគវា

ឥតិបិ មេត្តាបរមត្ថបារមីសម្បន្នោ សោ ភគវា

១០- ឥតិបិ ឧបេក្ខាបារមីសម្បន្នោ សោ ភគវា

ឥតិបិ ឧបេក្ខាឧបបារមីសម្បន្នោ សោ ភគវា

ឥតិបិ ឧបេក្ខាបរមត្ថបារមីសម្បន្នោ សោ ភគវា

➢ ឥតិបិ ទសបារមីសម្បន្នោ សោ ភគវា

ឥតិបិ ទសឧបបារមីសម្បន្នោ សោ ភគវា

ឥតិបិ ទសបរមត្ថបារមីសម្បន្នោ សោ ភគវា

ឥតិបិ សមត្តឹសបារមីសម្បន្នោ សោ ភគវា ។

# បដិច្ចសមុប្បាទធម៌

❖ អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ
វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ
សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា
វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ
ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ
ជាតិប្បច្ចយា ជរាមរណំ, សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ, ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

❖ អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ
សង្ខារនិរោធា វិញ្ញាណនិរោធោ
វិញ្ញាណនិរោធា នាមរូបនិរោធោ
នាមរូបនិរោធា សឡាយតននិរោធោ
សឡាយតននិរោធា ផស្សនិរោធោ
ផស្សនិរោធា វេទនានិរោធោ
វេទនានិរោធា តណ្ហានិរោធោ
តណ្ហានិរោធា ឧបាទាននិរោធោ
ឧបាទាននិរោធា ភវនិរោធោ
ភវនិរោធា ជាតិនិរោធោ
ជាតិនិរោធា ជរាមរណំ,
សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ
ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

# ពុទ្ធជយមង្គលគាថា

១- ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ
គ្រីមេខលំ ឧទិតឃោរសសេន មារំ
ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

២- មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ
ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ
ខន្តីសុទន្តវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៣- នាឡាគិរឹ គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៤- ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវន្តិ យោជនបថង្គុលិមាលវន្តំ
ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៥- កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា
ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ
សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៦- សច្ចំ វិហាយ មតិសច្ចកវាទកេតុំ
វាទាភិរោបិតមនំ អតិអន្ធភូតំ
បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៧- នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ទមាបយន្តោ
ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៨- ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៩- ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា
យោ វាចនោ ទិនទិនេ សរតេ មតន្ទី
ហិត្វានេកវិវិធានិ ចុបទ្ទវានិ
មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ ។

*គាថានេះមិនមានក្នុងបិដក អដ្ឋកថា ដីកាទេ ប៉ុន្តែអ្នកវិជ្ជាការខ្លះសន្និដ្ឋានថា ប្រព័ន្ធឡើងក្នុងរវាងពុទ្ធសករាជ ២០០៦ ដោយព្រះមហាពុទ្ធសិរិត្ថេរ អ្នករចនាគម្ពីរដីកាពាហុំ ។ គាថានេះនិយាយអំពីជ័យជម្នះរបស់ព្រះសម្មាសម្ពុទ្ធ៨ដងទៅលើកពួកមារជាដើម។ ចំណែកគាថាទី៩ ទើបតែងឡើងសម័យខាងក្រោយ ព្រោះមិនប្រាកដក្នុងដីកាពាហុំ ។*

# ជយបរិត្តគាថា

## គាថាពោលអំពីជ័យជម្នះរបស់ព្រះពុទ្ធ

១- មហាការុណិកោ នាថោ ហិតាយ សព្វបាណិនំ
បូរេត្វា បារមី សព្វា បត្តោ សម្ពោធិមុត្តមំ
ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ ។

២- ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ
ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ

៣- អបរាជិតបល្លង្កេ សីសេ បថវិបោក្ខរេ
អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ

៤- សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ

៥- បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ
បទក្ខិណំ មនោកម្មំ បណិធី តេ បទក្ខិណា
បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ ។

៦- តេ អត្ថលទ្ធា សុខិតា វិរុឡ្ហា ពុទ្ធសាសនេ
អរោគា សុខិតា ហោថ សហ សព្វេហិ ញាតិភិ ។

*<u>បញ្ជាក់</u> : គាថាទី ១ ដល់ទី ៣ បោរាណាចារ្យប្រព័ន្ធឡើង, គាថាទី ៤ ដល់ទី ៦ ជាពុទ្ធវចនៈ មានក្នុងបុព្វណ្ហសូត្រ (បិ.៤១/៤៧៦) ។*

# អភយបរិត្តគាថា

## គាថាការពារកុំឱ្យមានភ័យ

យន្ទុន្និមិត្តំ អវមង្គលញ្ច
យោ ចាមនាបោ សកុណស្ស សទ្ទោ
បាបគ្គហោ ទុស្សុបិនំ អកន្តំ
ពុទ្ធានុភាវេន ធម្មានុភាវេន
សង្ឃានុភាវេន វិនាសមេន្តុ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។
ឯត្តាវតា ច អម្ហេហិ សម្ភតំ បុញ្ញសម្បទំ
សព្វេ ទេវានុមោទន្តុ សព្វសម្បត្តិសិទ្ធិយា ។
ទានំ ទទន្តុ សទ្ធាយ សីលំ រក្ខន្តុ សព្វទា
ភាវនាភិរតា ហោន្តុ គច្ឆន្តុ ទេវតា គតា ។
សព្វេ ពុទ្ធា ពលប្បត្តា បច្ចេកានញ្ច យម្ពលំ
អរហន្តានញ្ច តេជេន រក្ខំ ពន្ធាមិ សព្វសោ ។

*- គាថានេះ បោរាណាចារ្យ ប្រព័ន្ធឡើងអាងគុណព្រះរតនត្រ័យ មកគ្រប់គ្រងរក្សាឲ្យមានសិរីសួស្ដី ។*

# សព្វមង្គលគាថា

១- **ភវតុ សព្វមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វពុទ្ធានុភាវេន សទា សោត្ថី ភវន្តុ តេ ។**
២- **ភវតុ សព្វមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វធម្មានុភាវេន សទា សោត្ថី ភវន្តុ តេ ។**
៣- **ភវតុ សព្វមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វសង្ឃានុភាវេន សទា សោត្ថី ភវន្តុ តេ ។**

*- ជាគាថារបស់បោរាណាចារ្យប្រព័ន្ធឡើង ។*

**រម្លឹកបន្ថែម**

*លុះសូត្រធម៌ខាងលើនេះចប់ហើយ បើមានពេលវែង និងមានអ្នកណាចេះចាំនូវធម៌* **រតនមាលា** *ដែលពោលអំពីគុណព្រះពុទ្ធ៥៦គាថា ពោលពីគុណព្រះធម៌ ៣៨ គាថា និងពោលពីគុណព្រះសង្ឃ ១៤ គាថា ដែលបោរាណាចារ្យបានប្រព័ន្ធឡើងចេញពីធម៌* **ឥតិបិសោ, ស្វាក្ខាតោ,** *និង* **សុបដិបន្នោ** *។ម្យ៉ាងទៀតគប្បីសូត្រគាថា* **ជិនបញ្ជរ** *ជាគាថាដែលថេរៈសម័យដើមតែងស្វាធ្យាយ ក្នុងពិធីផ្សេង ៗ មានពុទ្ធាភិសេកជាដើម ។ គាថានេះ ពោលអារាធនាព្រះពុទ្ធ ព្រះសាវ័ក និងព្រះបរិត្តឲ្យមកទ្រទ្រង់នៅក្នុងកាយ ដើម្បីគ្រប់គ្រងឲ្យមានសិរីសួស្តី ទុកដូចជាគ្រោះកែវដ៏វិសេស ការពារភ័យ ។*



ព្រះអង្គបរិនិព្វាន

# បកិណ្ណកធម៌

បន្ទាប់ពីចប់កិច្ចវេរគ្រឿងសក្ការបូជា ថ្វាយចំពោះព្រះរតនត្រ័យហើយ គប្បីសូត្រធម៌ផ្សាយមេត្តា បត្តិទានគាថា បត្ថនាគាថា និងសុខាភិយាចនគាថា ជាដើម។ បើមានពេលច្រើន គួរសូត្របាលីគាថា និងកំណាព្យក្នុង **បកិណ្ណកធម៌** ខាងក្រោយផង ដើម្បីញ៉ាំងសេចក្តីជ្រះថ្លាក្នុងគុណព្រះត្រៃរតន៍ និងជាទីចម្រើនបុណ្យកុសលបន្ថែមទៀត ។

## បកាសនកថា

**បញ្ចមារេ ជិនោ នាថោ　　បត្តោ សម្ពោធិមុត្តមំ**
**ចតុសច្ចំ បកាសេន្តោ　　ធម្មចក្កំ បវត្តយិ**
**ឯតេន សច្ចវជ្ជេន　　ហោតុ មេ ជយមង្គលំ ។**

វីអង្គព្រះលោកនាថ　　មុនីជាតិពង្សពុទ្ធា
ជាម្លប់នៃសត្តា　　ទ្រង់ផ្ចាញ់មារគ្រប់ទាំងប្រាំ ។
ទ្រង់ឈ្នះដោយជោគជ័យ　　មានព្រះទ័យតម្កល់មាំ
សម្រេចគុណដ៏ធំ　　ពោធិញ្ញាណជាសាស្តា ។
ព្រះអង្គទ្រង់ប្រកាស　　ធម៌ពិតច្បាស់បួនប្រការ
ប្រោសសត្វមនុស្សទេវតា　　តាមមាគ៌ាអង្គប្រាំបី ។
ញ៉ាំងចក្រគឺព្រះធម៌　　ជាយានបរចាកលោកិយ
នាំសត្វក្នុងភពបី　　ដាក់ដល់ត្រើយគឺនិព្វាន ។

ដោយសច្ចវាចា ចិត្តប្រាថ្នាប្រណិធាន
សូមទាន់ព្រះទ្រង់ញាណ ត្រាស់ខាងក្រោយពិតប្រាកដ ។
បានស្ដាប់ធម៌ព្រះអង្គ យល់ត្រូវត្រង់ស្អាតហ្មត់ចត់
បញ្ចប់សង្សារវដ្ដ លែងវិលបត់ត្រលប់សា ។
តែបើមិនទាន់ដល់ ជួបមគ្គផលដូចប្រាថ្នា
សូមគុណធម៌ថ្លៃថ្លា ជួយរក្សាឲ្យសុខសាន្ត ។
សូមជួបជ័យមង្គល កុំឲ្យយល់ទុក្ខរំខាន
សត្រូវទាំងប៉ុន្មាន សូមប្រែប្រាណមានចិត្តល្អ ។
សូមសុខសន្តិភាព កើតរៀងរាបជាស្ថាពរ
ដល់សព្វសត្វនិករ គ្រប់ភពឋានសព្វៗកាល ។

*(ដោយឧបាសក ជួន-ម៉ែន)*

## សម្បសាទនកថា

ខ្ញុំសូមនមស្ការ ចិត្តជ្រះថ្លាបង្គំផ្ចង់
ព្រះត្រៃសរណគមន៍ គ្រប់ដោយអង្គប្រជុំបី ។
ទីមួយគឺព្រះពុទ្ធ ប្រសើរផុតក្នុងលោកិយ
ត្រាស់ដឹងដោយបារមី មានព្រះទ័យមហាករុណា ។
ស្រង់សត្វចេញចាកលោក ដែលផុយផោកដោយអវិជ្ជា
ទេសនាព្រះធម្មា ឆ្លងសង្សារឥតសង្ស័យ ។
បពិត្រព្រះមានជោគ សត្វក្នុងលោកជ្រះថ្លាក្រៃ

បូជាទាំងយប់ថ្ងៃ.　　ជាបច្ច័យដល់និព្វាន ។
ទីពីរគឺព្រះធម៌　　ប្រសើរល្អប្រៀបពុំបាន
ព្រះធម៌ដូចជាស្ពាន　　ឬជាយានចម្លងសត្វ ។
ដូច្នេះយើងរាល់គ្នា　　ប្រឹងសិក្សានិងបដិបត្តិ
ពិចារណាដោយហ្មត់ចត់　　ទើបឆ្លងផុតពីទុក្ខា ។
ទីបីគឺព្រះសង្ឃ　　លោកទ្រទ្រង់ត្រៃសិក្ខា
សង្រួមកាយវាចា　　បដិបត្តិធម៌វិន័យ ។
សរណៈល្អឧត្តម　　ឱនបង្គំប្រជុំបី
ព្រះពុទ្ធព្រះធម៌ថ្លៃ　　ព្រះសង្ឃក្តីប្រសើរផុត ។
យើងខ្ញុំទាំងអស់គ្នា　　សូមបូជាព្រះត្រៃរតន៍
មានមកពិតប្រាកដ　　គ្រប់ដោយបទបីប្រការ ។
ជាកែវដ៏ឧត្តម　　នាំសុខធំដល់សត្តា
ដែលមានចិត្តជ្រះថ្លា　　ផុតសង្សារនោះឯងហោង ។

***(ដោយ ហេង-ជុំនិត និង គល់-សុភាព)***

## រតនប្បសំសាកថា

**ចិត្តីកតំ មហគ្ឃញ្ច អតុលំ ទុល្លភទស្សនំ**
**អនោមសត្តបរិភោគំ រតនំ តេន វុច្ចតិ ។**

*វត្ថុដែលធ្វើឲ្យគេរីករាយ មានតម្លៃច្រើន ថ្លឹងមិនបាន ឃើញបានដោយលំបាក មិនជាការបរិភោគរបស់សត្វអ្នកថោកទាប ដោយហេតុនោះ ទើបហៅថា រតនៈ ។*

**ពុទ្ធោតិ វចនំ សេដ្ឋំ ពុទ្ធោតិ បទមុត្តមំ**
**នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ ។**

*ពាក្យថា ព្រះពុទ្ធ ជាពាក្យដ៏ប្រសើរបំផុត បទថា ព្រះពុទ្ធ ជាបទដ៏ខ្ពង់ខ្ពស់បំផុត ពាក្យនិងបទដទៃ ដែលពីរោះដល់ត្រចៀក ស្មើដោយពាក្យនិងបទនោះ ក្នុងលោក មិនមានឡើយ ។*

**ធម្មោតិ វចនំ សេដ្ឋំ ធម្មោតិ បទមុត្តមំ**
**នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ ។**

*ពាក្យថា ព្រះធម៌ ជាពាក្យដ៏ប្រសើរបំផុត បទថា ព្រះធម៌ ជាបទដ៏ខ្ពង់ខ្ពស់បំផុត ពាក្យនិងបទដទៃ ដែលពីរោះដល់ត្រចៀក ស្មើដោយពាក្យនិងបទនោះ ក្នុងលោក មិនមានឡើយ ។*

**សង្ឃោតិ វចនំ សេដ្ឋំ សង្ឃោតិ បទមុត្តមំ**
**នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ ។**

ពាក្យថា ព្រះសង្ឃ ជាពាក្យដ៏ប្រសើរបំផុត បទថា ព្រះសង្ឃ ជាបទដ៏ខ្ពង់ខ្ពស់បំផុត ពាក្យនិងបទដទៃ ដែលពីរោះដល់ត្រចៀក ស្មើដោយពាក្យនិងបទនោះ ក្នុងលោក មិនមានឡើយ ។ (រតនសុត្តដ្ឋកថា)

**អប្បមាណោ ពុទ្ធោ**

ព្រះពុទ្ធ ទ្រទ្រង់នូវព្រះគុណ នឹងប្រមាណមិនបាន ។

**អប្បមាណោ ធម្មោ**

ព្រះធម៌ ទ្រទ្រង់នូវព្រះគុណ នឹងប្រមាណមិនបាន ។

**អប្បមាណោ សង្ឃោ**

ព្រះសង្ឃ ទ្រទ្រង់នូវព្រះគុណ នឹងប្រមាណមិនបាន ។

**ឥទម្បិ ពុទ្ធេ រតនំ បណីតំ** កែវគឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម

**ឥទម្បិ ធម្មេ រតនំ បណីតំ** កែវគឺព្រះធម៌នេះឯង ជាកែវដ៏ឧត្តម

**ឥទម្បិ សង្ឃេ រតនំ បណីតំ** កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

## បណាមគាថា

**សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វទុក្ខស្ស បហានាយ**

**ធម្មំ ទេសេតិ តំ សម្មាសម្ពុទ្ធំ អាទរេន នមស្សាម ។**

ព្រះភគវន្តមុនីអង្គឯណា ទ្រង់ត្រាស់សម្តែងនូវធម៌ដើម្បីកម្ចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធមែនពិត យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

**និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខស្ស បហានាយ**
**ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អាទរេន នមស្សាម ។**

ព្រះធម៌ឯណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សម្តែងហើយ ដោយប្រពៃ ដើម្បីកម្ចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វមែនពិត យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះធម៌នោះ ដោយគោរព ។

**សុបដិបន្នោ វតស្ស ភគវតោ សោ សាវកសង្ឃោ យោ សព្វ-**
**ទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ អាទរេន នមស្សាម ។**

ព្រះអរិយសង្ឃឯណា លោកប្រតិបត្តិដើម្បីកម្ចាត់បង់ នូវសេចក្តីទុក្ខទាំងពួង ព្រះអរិយសង្ឃនោះជាសង្ឃសាវ័ក នៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិ ដោយប្រពៃមែនពិត យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយគោរព ។ (វិសាខបូជាបោត្ថកេ)

**វន្ទិត្វា សិរសា សេដ្ឋំ　ពុទ្ធមប្បដិបុគ្គលំ**
**ញេយ្យសាគរមុត្តិណ្ណំ　តិណ្ណសំសារសាគរំ ។**

ខ្ញុំព្រះអង្គ សូមថ្វាយបង្គំដោយសិរសាគឺត្បូង ចំពោះព្រះសព្វញ្ញុ-ពុទ្ធ ទ្រង់ប្រសើរផុតឥតបុគ្គលប្រៀបបាន ទ្រង់បានឆ្លងផុតសង្សារ-សាគរ ឡើងទៅកាន់សាគរគឺញេយ្យធម៌ហើយ ។

**តថេវ បរមំ សន្តំ　គម្ភីរំ ទុទ្ទសំ អណុំ**
**ភវាភវករំ សុទ្ធំ　ធម្មំ សទ្ធម្មបូជិតំ ។**

មួយទៀត សូមថ្វាយបង្គំ ចំពោះព្រះធម៌ថ្លៃ ជាធម៌រម្ងាប់បង់នូវរាគាទិក្កិលេស ជាធម៌ល្អិតជ្រាលជ្រៅ កម្រសត្វឃើញបានដោយងាយ ជាធម៌ធ្វើនូវភពតូចនិងភពធំ ឲ្យជ្រះស្រឡះ ជាព្រះសទ្ធម្មដែលទេវតានិងមនុស្សតែងបូជា ។

**តថេវ បន សង្ឃញ្ច  អសន្តំ សង្ឃមុត្តមំ**
**ឧត្តមំ ទក្ខិណេយ្យានំ  សន្តិន្ទ្រិយំ អនាសវំ ។**

មួយវិញទៀត សូមថ្វាយបង្គំ ចំពោះព្រះសង្ឃ ដែលមិនមានការជាប់ចំពាក់ដោយរាគាទិក្កិលេស ជាព្រះសង្ឃខ្ពង់ខ្ពស់ ប្រសើរជាងទក្ខិណេយ្យបុគ្គលទាំងឡាយ ជាព្រះសង្ឃមានឥន្ទ្រិយស្ងប់រៀបរយ ជាព្រះសង្ឃមិនមានអាសវក្កិលេស ។ (ពុទ្ធប្បវត្តិ ទូរេនិទាន)

**ពុទ្ធោ តិលោកសរណោ  ពុទ្ធោ សេដ្ឋោ វរោត្តមោ**
**ពុទ្ធោ លោកវរជេដ្ឋោ  អហំ វន្ទាមិ សព្វទា ។**

ព្រះពុទ្ធជាម្ចាស់ទ្រង់ជាទីពឹងនៃត្រៃលោក ព្រះពុទ្ធទ្រង់ប្រសើរឧត្តមខ្ពង់ខ្ពស់ ព្រះពុទ្ធទ្រង់ចម្បងដ៏ប្រសើរក្នុងលោក ខ្ញុំសូមថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់អង្គនោះ សព្វកាលទាំងពួង ។

**ធម្មោ តិលោកសរណោ  ធម្មោ សេដ្ឋោ វរោត្តមោ**
**ធម្មោ លោកវរនាថោ  អហំ វន្ទាមិ សព្វទា ។**

ព្រះធម៌ជាទីពឹងនៃត្រៃលោក ព្រះធម៌ប្រសើរឧត្តមខ្ពង់ខ្ពស់ ព្រះធម៌ជាទីពឹងដ៏ប្រសើរក្នុងលោក ខ្ញុំសូមថ្វាយបង្គំនូវព្រះធម៌នោះ សព្វកាលទាំងពួង ។

**សង្ឃោ តិលោកសរណោ សង្ឃោ សេដ្ឋោ វរោត្តមោ**
**សង្ឃោ លោកេ អនុត្តរោ អហំ វន្ទាមិ សព្វទា ។**

*ព្រះសង្ឃជាទីពឹងនៃត្រៃលោក ព្រះសង្ឃប្រសើរឧត្តមខ្ពង់ខ្ពស់ ព្រះសង្ឃដ៏ប្រសើរក្នុងលោក ខ្ញុំសូមថ្វាយបង្គំនូវព្រះសង្ឃនោះ សព្វកាលទាំងពួង ។* (គ្រូជម្មានន្ទ)

## បណាមគាថា

**ពុទ្ធោ មហេសី អរហំ តថាគតោ**
**លោកុត្តមោ សព្វគរូហិ ជេដ្ឋកោ**
**លោកស្ស សត្ថា ជនតម្ពកោវិទោ**
**វន្ទាមហំ តំ នរបូជនេយ្យកំ ។**

*អរហន្តតថាគត ជ្រាបគ្រប់បទស្វែងគុណធំ*
*ទ្រង់ជាលោកុត្តម ច្បងជាងសព្វគ្រូលើសលន់ ។*
*ជាសាស្តានៃលោក ចេះឥតស្មោកទូន្មានជន*
*ខ្ញុំវន្ទាបន្ទន់ ទ្រង់ដែលជនគួរបូជា ។*

**ធម្មោ បទីបោ វយ តស្ស សត្ថុនោ**
**លោកានមន្ធស្ស វិនាសការកោ**
**សព្វញ្ញុពុទ្ធប្បជិតូតិ សញ្ញតោ**
**វន្ទាមហំ តំ នរបូជនេយ្យកំ ។**

ព្រះធម៌នៃសាស្តា ឧបមាដូចពន្លឺ
តែងធ្វើលោកឲ្យភ្លឺ ចាកងងឹតឲ្យស្ងួនផុត ។
ដែលប្រាជ្ញសម្គាល់អាង ថាតំណាងសព្វញ្ញុពុទ្ធ
ខ្ញុំវន្ទាលំអុត ធម៌នោះសុទ្ធជនបូជា ។

**សង្ឃោ វិសុទ្ធោ សុគតស្ស សាវកោ**
**សិក្ខាសុ ភាវោ វរធម្មសិក្ខកោ**
**និទ្ទោបសំសាទិអនាគរោ វរោ**
**វន្ទាមហំ តំ នរបូជនេយ្យកំ ។**

សាវ័កព្រះសុគត ស្អាតហ្មត់ចត់វិសេសថ្លា
ប្រាជ្ញាត្រៃសិក្ខា លោកសិក្សាធម៌ឧត្តម ។
ជាសង្ឃថ្នាក់ខាងលើ មិនអើពើលោកធម្ម
ខ្ញុំវន្ទាប្រណម្យ សង្ឃឧត្តមជនបូជា ។

**នមក្ការានុភាវេន វឌ្ឍតុ ពុទ្ធសាសនំ**
**សមគ្គោ ហោតុ សង្ឃោ ច សុខី ហោន្តុ ច សាធវោ ។**

ដោយអំណាចវន្ទា ត្រៃរតនាជាអម្ចាស់
សូមឲ្យពុទ្ធសាសន៍ លូតលាស់ក្រាស់ចម្រើនផង ។
សូមឲ្យសង្ឃព្រមព្រៀង កុំឲ្យល្អៀងខុសគន្លង
សូមសាធុជនផង កុំមានហ្មងបានសុខុម ។

**រតនត្តយតេជេន សិក្ខា មេ ឯតុ វឌ្ឍនំ**
**តស្សាបិ អានុភាវេន សហសាយេវ សិជ្ឈតុ ។**

ដោយតេជះត្រៃរតន៍ ខ្ញុំប្រណិប័តន៍ដោយគោរព
សូមឲ្យការរៀនគ្រប់ របស់ខ្ញុំបានវឌ្ឍនា ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទា
សូមឲ្យការសិក្សា របស់ខ្ញុំសម្រេចឆាប់ ។
**រោគា ចេវន្តរាយា ច ឧប្បន្នា ចេ ឧបទ្ទវា**
**ពុទ្ធាទិអានុភាវេន វិនស្សន្តុ អសេសតោ ។**
ដោយតេជះត្រៃរតន៍ មានពុទ្ធរតន៍ជាប្រធាន
ប្រសិនបើកើតមាន អន្តរធានចង្រៃរោគ
សូមឲ្យវិនាសខ្ពោក កុំសល់រោគតិចតួចឡើយ ។

## សុខាភិយាចនគាថា

**ពុទ្ធំសុមាលី ទិបនុត្តមោ តមោ**
**ហន្ត្វាន ពោធេសិធ បន្ថជំ កជំ**
**មគ្គគ្គសេលម្ហិ សុទុដ្ឋិតោ ឋិតោ**
**សោ មំ ចិរំ បាតុ សុខំ សទា សទា ។**

ព្រះពុទ្ធដូចអាទិត្យ ឧត្តមពិតជាងពួកជន
កម្ចាត់នូវមោហន្ធ ហើយចេញចាកសព្វកិលេស ។
ទ្រង់ឋិតនៅលើភ្នំ ដ៏ឧត្តមមគ្គវិសេស
ដាស់សត្វជាប់កិលេស ឲ្យភ្លឺថែសក្នុងលោកា ។
សូមទ្រង់ប្រោសគ្រប់គ្រង យើងខ្ញុំផងរាល់វេលា

ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។

**ស្វាក្ខាតធម្មោ វិមលោ សុនិម្មលោ**
**សន្ទិដ្ឋិកោ សន្តិករោ ធុវង្គរោ**
**បូជារហោ មោក្ខនយោ សុខន្ទយោ**
**សោ មំ ចិរំ បាតុ សុខំ សទា សទា ។**

ស្វាក្ខាតធម៌ណា ផ្លូវជង់ថ្លាគ្មានសៅហ្មង
ជាធម៌ដែលអ្នកផង ឃើញច្បាស់ពិតដោយខ្លួនឯង ។
ធ្វើនូវសន្តិភាព ធុវភាពដ៏ចំពោ្ងង
គួរបូជាយ៉ាងស្តែង ឲ្យនិព្វានឲ្យសុខា ។
សូមធម៌នោះគ្រប់គ្រង ឃើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។

**សង្ឃោ វិសុទ្ធោ សុភរោ សយម្ភរោ**
**ពុទ្ធស្ស បុត្តោ សុជហោ រណញ្ជហោ**
**ខេត្តញ្ជនានំ សវកោ សុសាវកោ**
**សោ មំ ចិរំ បាតុ សុខំ សទា សទា ។**

រីព្រះអរិយសង្ឃ ជាបុត្រអង្គព្រះសម្ពុទ្ធ
លោកស្អាតបរិសុទ្ធ ផាយចិញ្ចឹមរៀងរាល់ផ្ទះ ។
ចិញ្ចឹមដោយអាត្មា កិលេសាលះស្រឡះ
សង្គ្រាមក៏លោកលះ ជ្រះស្រឡះបានក្បៀមក្សាន្ត ។

ជាអ្នកស្តាប់ឱវាទ ដែលលោកនាថទ្រង់ទូន្មាន
ជាសាវ័កកល្យាណ ស្រែបុណ្យទាននៃជនា ។
សូមសង្ឃនោះគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។

(ចាកបាលីវេយ្យាករណ៍)

## ឱភាសនគាថា

**ពុទ្ធោ តិលោកទីបោច ពុទ្ធោ សុរិយោ តមោនុទោ**
**យេ យន្តិ សរណំ ពុទ្ធំ នត្ថិ តេសំ ភយំ សទា ។**
ព្រះពុទ្ធដូចប្រទីប បំភ្លឺទីបនាលោកិយ
ឲ្យសត្វក្នុងភពបី ជួបសួស្តីសុមង្គល ។
ដូចជាសែងសុរិយា រះភ្លឺថ្លាភពមណ្ឌល
សព្វសត្វបានដឹងយល់ នូវហេតុផលគ្រប់ប្រការ ។
បំបាត់ភាពងងឹត ឃើញច្បាស់ពិតនូវមាគ៌ា
បំពេញកិច្ចការងារ បានសុខាល្អប្រពៃ ។
អ្នកណាដល់ព្រះពុទ្ធ គុណវិសុទ្ធស្អាតថ្លាថ្លៃ
អ្នកនោះរួចទុក្ខភ័យ គ្រោះចង្រៃសព្វរោគា ។
បានជួបសុខសួស្តី ជោគសិរីតាមប្រាថ្នា
សម្បត្តិទ្រព្យនានា កើតបរិបូរសព្វកាលហោង ។
**ធម្មោ តិលោកទីបោច ធម្មោ សុរិយោ តមោនុទោ**
**យេ យន្តិ សរណំ ធម្មំ នត្ថិ តេសំ ភយំ សទា ។**

ព្រះធម៌ដូចប្រទីប បំភ្លឺទីបនាលោកិយ
ឲ្យសត្វក្នុងភពបី ជួបសួស្ដីសុមង្គល ។
ដូចជាសែងសុរិយា រះភ្លឺថ្លាភពមណ្ឌល
សព្វសត្វបានដឹងយល់ នូវហេតុផលគ្រប់ប្រការ ។
បំបាត់ភាពងងឹត ឃើញច្បាស់ពិតនូវមាគ៌ា
បំពេញកិច្ចការងារ បានសុខាល្អប្រពៃ ។
អ្នកណាដល់ព្រះធម៌ បរិសុទ្ធល្អឥតឧបមេយ្យ
អ្នកនោះរួចទុក្ខភ័យ គ្រោះចង្រៃសព្វរោគា ។
បានជួបសុខសួស្ដី ជោគសិរីតាមប្រាថ្នា
សម្បត្តិទ្រព្យនានា កើតបរិបូរសព្វកាលហោង ។
**សង្ឃោ តិលោកទីបោវ សង្ឃោ សុរិយោ តមោនុទោ**
**យេ យន្តិ សរណំ សង្ឃំ នត្ថិ តេសំ ភយំ សទា ។**
ព្រះសង្ឃដូចប្រទីប បំភ្លឺទីបនាលោកិយ
ឲ្យសត្វក្នុងភពបី ជួបសួស្ដីសុមង្គល ។
ដូចជាសែងសុរិយា រះភ្លឺថ្លាភពមណ្ឌល
សព្វសត្វបានដឹងយល់ នូវហេតុផលគ្រប់ប្រការ ។
បំបាត់ភាពងងឹត ឃើញច្បាស់ពិតនូវមាគ៌ា
បំពេញកិច្ចការងារ បានសុខាល្អប្រពៃ ។
អ្នកណាដល់ព្រះសង្ឃ លោកទ្រទ្រង់សិក្ខា ៣

អ្នកនោះរួចទុក្ខភ័យ គ្រោះចង្រៃសព្វរោគា ។
បានជួបសុខសួស្តី ជោគសិរីតាមប្រាថ្នា
សម្បត្តិទ្រព្យនានា កើតបរិបូរសព្វកាលហោង ។

(ឧបាសក ជួន-ម៉េន)

## ធម្មបទគាថា

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។**

ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ការសម្តែងព្រះសទ្ធម្ម ជាសុខ សេចក្តីព្រមព្រៀងគ្នានៃពួក ( សង្ឃ ឬពួកក្រុម ) ជាសុខ សេចក្តីព្រម-ព្រៀងគ្នា របស់អ្នកមានតបធម៌ទាំងឡាយ ជាសុខ ។

**បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ**
**បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ**
**តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ**
**ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។**

កាលបុគ្គលបូជាដល់បូជារហបុគ្គល គឺព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោក និងខ្សឹកខ្សួល ឬកាលបូជាដល់បូជារហបុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណា សូម្បីនិព្វានទៅហើយ បុគ្គលណាមួយមិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណោះបានឡើយ ។ **(ធម្មបទ ពុទ្ធវគ្គ)**

## ពុទ្ធុប្បត្តិកថា

សុខោពុទ្ធានមុប្បាទោ ព្រះពុទ្ធផ្ការពោរពេញក្លាហាន
កសាងបារមីសិរីថ្កើងថ្កាន រហូតដល់បានត្រាស់ជាព្រះពុទ្ធ ។
ព្រះពុទ្ធគ្រប់អង្គត្រាស់ដឹងក្នុងលោកមានជ័យមានជោគប្រាជ្ញាមោះមុត
ព្រះអង្គឈ្នះមារនៅពេលប្រយុទ្ធ ដោយសស្ត្រាវុធមុតគ្មានអ្វីដូច ។
ទ្រង់ត្រាស់ដឹងហើយនាំមកនូវសុខ បំបែកសម្បកទិដ្ឋិកំហូច
ដោយធម៌ទេសនាភ្លឺថ្លារុងរោចន៍ សុខគ្មានអ្វីដូចគឺព្រះនិព្វាន ។

## ល្អបីប្រការ

ល្អក្នុងសាសនា មានបីប្រការ ព្រះអង្គសម្តែង
ទេសនាទុកមក ប្រាកដជាក់ស្តែង ឲ្យសត្វខំស្វែង
ទុកក្នុងសន្តាន ។
ល្អបទខាងដើម ប្រសើរយ៉ាងឆ្នើម គឺសីលកល្យាណ
ខិតខំរក្សា ឃុំគ្រងឲ្យបាន ផលនោះនាំប្រាណ
បានសុគតិភព ។
ល្អបទកណ្តាល ល្អយ៉ាងត្រកាល ភាវនាគ្មានឈប់
ចម្រើនកម្មដ្ឋាន ឲ្យបានសព្វគ្រប់ រាល់ពេលថ្ងៃយប់
ស្ងប់ក្នុងព្រះធម៌ ។
ល្អបទខាងចុង ចម្រើនទុកក្នុង បញ្ញាឧត្តម

បានយល់ចាក់ធ្លុះ នូវព្រះសទ្ធម្ម សតិតាំងមាំ
ចងចាំយល់បាន ។
ដឹងនូវលក្ខណៈ ភាវៈប្រចក្ស ប្រចាំសន្តាន
សង្ខារតាក់តែង បញ្ញាចាំបាន កិលេសប៉ុន្មាន
យល់បានគ្មានសល់ ។
រំដោះកងទុក្ខ ប្រាថ្នាក្តីសុខ បញ្ញាតម្កល់
ចម្រើនអរិយមគ្គ នោះទើបបានដល់ ផុតទុក្ខកង្វល់
ដល់ទីក្សេមក្សាន្ត ។
នរអ្នកណា ព្យាយាមសិក្សា ល្អបីឲ្យបាន
ចងចាំក្នុងចិត្ត ទុកក្នុងសន្តាន ផលនោះនាំប្រាណ
បានសុខស្ងប់ហោង ។

*(ដោយឧបាសក ថូវ-ប៊ិន់)*

## ពុទ្ធកិច្ច ៥ យ៉ាង

**បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ**
**បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហានំ**
**បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ**
**ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោតិ ។**

ពុទ្ធកិច្ច ៥ យ៉ាងគឺអ្វីខ្លះ ចូរចាំឲ្យច្បាស់គ្រប់រូបា
បំណាច់អ្នកកាន់ពុទ្ធសាសនា ត្រូវចាំកិច្ចការនៃព្រះអង្គ ។

ពេលព្រឹកទ្រង់យាងបិណ្ឌបាត តាមផ្ទះមានញាតិចាំរហង់
ចូនមួយអង្គឯងចូនមានសង្ឃ តម្រង់តាមសត្វមាននិស្ស័យ ។
រសៀលទ្រង់ត្រាស់សម្ដែងធម៌ ដល់សត្វនិករដោយអាល័យ
បើសត្វមិនយល់ទ្រង់ឧបមេយ្យ បកស្រាយសេចក្ដីឲ្យយល់បាន ។
ព្រលប់ប្រទានព្រះឱវាទ ដល់សង្ឃឲ្យស្អាតល្អកល្យាណ
កុំឲ្យប្រព្រឹត្តខុសលំអាន តាមផ្លូវដែលបានទ្រង់បញ្ញត្ត ។
អធ្រាត្រទ្រង់ដោះស្រាយបញ្ហា ដែលពួកទេវតាមកច្រើនក្ដាត់
សម្ដែងព្រះសូត្រឬបរមត្ថ តាមពពួកសត្វដែលសង្ស័យ ។
ជិតភ្លឺប្រមើលនិស្ស័យសត្វ តើអាចប្រតិបត្តិមានកម្រៃ
ដែលគួរត្រាស់ដឹងព្រះធម៌ថ្លៃ តាមឧបនិស្ស័យសត្វលោកា ។
៤៥ ឆ្នាំ ឥតមានខ្វះ ព្រះអង្គនឿយណាស់លើសមនុស្សា
ឥតមានសម្រាកព្រះកាយា គឺគ្មាននរណាប្រដូចបាន ។
យើងបាត់ព្រះពុទ្ធទាន់សាសនា ធម៌ជាអាចារ្យទូន្មានប្រាណ
ប្រព្រឹត្តត្រង់ផ្លូវត្រូវលំអាន ដរាបដល់បាននិព្វានហោង ។

## ពុទ្ធកិច្ច ៥ យ៉ាង

គ្រាកាលព្រះសម្ពុទ្ធ ប្រសើរផុតដ៏ឧត្ដម
បានត្រាស់ជាបឋម សែសិបប្រាំព្រះវស្សា ។
បំពេញពុទ្ធកិច្ច មិនដែលដាច់វេលាណា
សន្មតឈ្មោះហៅថា ពុទ្ធក្រឹត្យាមានប្រាំយ៉ាង ។

ទី ១ គឺពេលព្រឹក ដ៏ពន្លឺកពន្លឺស្វាង
ព្រះអង្គស្តេចទ្រង់យាង ចេញបិណ្ឌបាតប្រោសសព្វសត្វ។
ទី ២ រសៀលជ្រេ ព្រះសុរិយេពេលទៀបស្វាត់
ទេសនាប្រោសសព្វសត្វ មិនកំណត់ថាសត្វណា ។
ទី ៣ ពេលព្រលប់ ព្រះចមកពត្រៃលោកា
ប្រទានធម៌ទេសនា ឲ្យឱវាទភិក្ខុសង្ឃ ។
ទី ៤ ពេលអធ្រាត្រ ព្រះលោកនាថទ្រង់ផ្ចិតផ្ចង់
ព្រះទ័យល្អស្មោះត្រង់ ទ្រង់ដោះស្រាយនូវប្រស្នា ។
ជម្រេងៗកើតឡើងពិត នៅក្នុងចិត្តនៃទេវតា
ងឿងឆ្ងល់ធម៌ត្រង់ណា ព្រះសាស្តាទ្រង់អារកាត់ ។
ទី ៥ ពេលទៀបភ្លឺ ប្រមើលមើលនិស្ស័យសត្វ
នៅក្នុងសង្សារវដ្ត ឲ្យប្រាកដគួរសន្តោស ។
សត្វណាមានសំណាង ព្រះអង្គយាងចេញទៅប្រោស
ប្រទានធម៌ទាបខ្ពស់ ឲ្យទៅតាមឧបនិស្ស័យ ។
ធម៌នោះឈ្មោះហៅថា ពុទ្ធក្រឹត្យាប្រសើរក្រៃ
វិជ្ជាទិវថ្លៃ នៃព្រះពុទ្ធពីបុរាណ ។
បំពេញឥតនឿយណាយ រៀងរាល់ថ្ងៃមិនដែលខាន
លុះព្រះចូលនិព្វាន ទើបឈប់ខានទាំងអស់ហោង ។
ហៃសាធុជនណា អ្នកប្រាថ្នានឹងប៉ុនប៉ង

ចង់ឃ្លាតពីចំណង ត្រៃលោកនេះពិតប្រាកដ ។
ត្រូវខំប្រឹងសិក្សា នូវធម៌អាថ៌ដែលជាបទ
ពុទ្ធកិច្ចប្រាំប្រាកដ នេះកំណត់គួរយល់ដឹង ។
ជននោះនឹងស្មើបាន នៅនាឋានជាទីពឹង
ឬនៅនាលោកហ្នឹង តែងបានខ្លួនជាអ្នកធំ ។
លើសជនជង់ទាំងឡាយ សុខសប្បាយដ៏ឧត្តម
ក្សេមក្សាន្តសុខមនោរម្យ រៀងរាបដល់និព្វានហោង ។

## សត្តមហាឋាន

**បឋមំ ពោធិបល្លង្កំ ទុតិយំ អនិមិសកំ**
**តតិយំ ចង្កមំ សេដ្ឋំ ចតុត្ថំ រតនឃរំ ។**
**បញ្ចមំ អជបាលញ្ច មុចលិន្ទេន ឆដ្ឋមំ**
**សត្តមំ រាជាយតនំ សត្ថាហំ មុនិ សេវិតំ ។**
**ឯតេ សត្ត មហាឋានេ ជម្ពូទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ ។**

ខ្ញុំសូមបង្គំប្រណម្យវន្ទា ឋានព្រះភគវ៉ានានាឆ្ងាយជិត
ឋានធំ៧ព្រះមុនីនៃបនិត្យ ឋានមួយទ្រង់ឋិតពិត១សប្តាហ៍ ។
សត្តមហាឋានមហាចេតិយ ពួកជនប្រុសស្រីគប្បីជ្រះថ្លា
ជាឋានបូជានៃពួកទេវតា ឋិតនៅអស្ចារ្យក្នុងជម្ពូទ្វីប ។
**បឋមំ ពោធិបល្លង្កំ** ទ្រង់តាំងបធានគ្មានស្តាយជន្មជីព

ត្រាស់ជាព្រះពុទ្ធផុតភ្លើងប្រទីប　មនុស្សជម្ពូទ្វីបមានលាភថ្លៃថ្លា ។
**ទុតិយំ　អនិមិសត្រ័**　ទ្រង់តាំងកាយឈរទិសបូពិឧត្តរា
នាព្រះពោធិព្រឹក្សមិនព្រិចនេត្រា　ទ្រង់ទតពិចារណ៍មហាឋានពុទ្ធោ ។
**តតិយំ　ចង្កមំ　សេដ្ឋំ**　ទ្រង់តាំងហឫទ័យក្នុងព្រៃព្រះពោធិ៍
ទ្រង់យាងទៅមកពីទីទ្រង់ឈរ　នឹកគល់ព្រះពោធិ៍ប្រពៃអស្ចារ្យ ។
**ចតុត្ថំ　រតនឃរំ**　ទ្រង់តាំងពលំកម្លាំងប្រាជ្ញា
ពុះជ្រែកអភិធម្មក្នុងផ្ទះរតនា　ពាយ័ព្យទិសានៃទីត្រាស់ដឹង ។
**បញ្ចមំ　អជ្ជបាលញ្ច**　ទ្រង់តាំងទ្រង់ដាក់ហឫទ័យនឹងធឹង
នៅទីទទួលបាយាសត្រាស់ដឹង　ខាងកើតដងស្ទឹងនេរញ្ជរា ។
**មុចលិន្ទេន　ឆដ្ឋមំ**　ទ្រង់តាំងបល្ល័ង្កគង់ក្នុងធម្មា
ខាងត្បូងព្រះពោធិ៍មាននាគរាជា　បាំងព្រះភគវាការពារភិរុណ ។
**សត្តមំ　រាជាយតនំ**　ទ្រង់តាំងធម្មំខ្លាំងក្លាដោយគុណ
ខាងត្បូងមុចលិន្ទព្រះឥន្ទ្រចុះមុន　បូជាព្រះគុណគង់ក្រោមដើមកែះ ។
សត្តមហាឋានមហាចេតិយ　សូត្ររៀងរាល់ថ្ងៃចម្រើនចំណេះ
ចម្រើនចិត្តស្ងប់រស់មិនប្រហែស　កាត់បង់កិលេសមានះឫស្យា ។
ព្រះពុទ្ធត្រាស់ដឹងទីពឹងក្នុងលោក　ផុតពីទុក្ខសោករាគរោគតណ្ហា
គង់ក្នុងឋានស្ងាត់ ៧ សប្តាហ៍　ចេតិយសម្មាសម្ពុទ្ធគ្រង់អគ្គ ។

*(ដោយលោកគ្រូ ប៊ុត សាវង្ស)*

## សហជាតវត្ថុ ៧ ប្រការ

| | |
|---|---|
| **១- រាហុលមាតា ទេវី** | *ព្រះនាងពិម្ពា រាហុលមាតា* |
| **២- អានន្ទោ រាជកុមារោ** | *ព្រះអានន្ទ រាជកុមារ* |
| **៣- ឆន្នោ អមច្ចោ** | *ឆន្នអាមាត្យ* |
| **៤- កាឡុទាយិ អមច្ចោ** | *កាឡុទាយីអាមាត្យ* |
| **៥- កណ្ឋកោ អស្សរាជា** | *សេះកណ្ឋកអស្សរាជ* |
| **៦- មហាពោធិរុក្ខោ** | *ព្រះស្រីមហាពោធិព្រឹក្ស* |
| **៧- ចតស្សោ និធិកុម្ភយោ** | *កំណប់ទ្រព្យទាំង ៤ ទិស ។* |

## ធម្មនិយាមសង្ខេប

*អហំ រី ខ្ញុំ បង្គំវន្ទា ឆ្ពោះព្រះភគវា ព្រះធម៌ថ្លៃថ្លា*

*ព្រមទាំងព្រះសង្ឃ ផូរផង់សីលា ចិន្ដាលំអុត ព្រះពុទ្ធនិយាម ។*

*សូមឲ្យសព្វសត្វ បដិបត្តិតាមធម៌ សាសនាបវរ ល្អដូចព្រះនាម*

*អរហំសម្មា គ្មានការទាក់ទាម កិលេសរវាម រវាតសូន្យបង់ ។*

*សូមឲ្យសាសនា សម្មាសម្ពុទ្ធ បរិសុទ្ធមោះមុត រួមចិត្តទ្រទ្រង់*

*ឋិតថេរចិរកាល អភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ ផ្ចិតផ្ចង់សិក្ខា ។ សូមមនុស្សទេវតា មានការគោរព ទាំងថ្ងៃទាំងយប់ ក្នុងព្រះសាសនា សូមបានសម្រេច ដូចក្ដីប្រាថ្នា អស់នូវតណ្ហា ទុក្ខាចប់ហោង ។* ***(ប៊ុត សាវង្ស)***

# ពុទ្ធប្បវត្តិសង្ខេប

**កុក្កុដេ គព្ភវាសោ ច-សោណេ ចុតនិក្ខមិ**
**ឧសភេ រាជសម្បត្តិ សសេ បព្វជិតោ ជិនោ។**

ព្រះវិជិតមារ ទ្រង់យាងចុះមកកាន់អាស្រ័យក្នុងព្រះគភ៌ (នៃព្រះមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតចាកព្រះគភ៌ ក្នុងឆ្នាំច ទ្រង់សោយរាជ-សម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

**កុក្កុដេ សព្វញ្ញូ ពុទ្ធោ តត្ថ ចក្កំ បវត្តយិ**
**និព្វានគមនំ សប្បេ សហស្សំ បញ្ច មូសិកេ។**

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងឆ្នាំរកា ទ្រង់សម្តែងនូវព្រះធម្មចក្រក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥០០០ គត់ក្នុងឆ្នាំជូត ។

**ឱក្កន្តោ ច គរុវារស្មឹ សុក្រវារេ ច និក្ខមិ**
**សម្ពុទ្ធោ ពុធវារស្មឹ អង្គារេ បរិនិព្វុតោ។**

ទ្រង់យាងចុះកាន់ព្រះគភ៌ (ព្រះមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ ។

**អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ**
**វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ។**

ព្រះអង្គយាងចុះកាន់ព្រះគភ៌ ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ប្រសូតក្នុងថ្ងៃពេញបូណ៌មីខែពិសាខ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណ៌មីខែពិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែពិសាខ ។

**និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ**
**បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ ។**
**ចតុរាសីតិសហស្ស- ធម្មក្ខន្ធា សុទេសិតា**
**អគ្គប្បវត្តនដ្ឋានេ ថបិតា ហោន្តិ បាណិនំ ។**

*កាលព្រះសម្មាសម្ពុទ្ធជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក ស្តេចបរិនិព្វានទៅហើយ ព្រះបដិមាផង ពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ម៉ឺន ៤ ពាន់ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្តែងហើយដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ក្នុងស្ថានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្ត ដ៏ប្រសើររបស់សត្វទាំងឡាយ ។*

**ឱកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពលវប្បច្ចូសសមយេ កុសិនារាយ យមកសាលានមន្តរេ អមុម្ហិ សប្បសំវច្ឆរេ គិម្ហឧតុម្ហិ វិសាខមាសេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធនក្ខត្តទិវសេ បរិនិព្វានំ អហោសិ អនុបាទិសេសាយ និព្វានធាតុយា ។**

*ខ្ញុំសូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុក្នុងចន្លោះសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារាក្នុងបច្ចូសសម័យដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្សឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាតិថីពេញបូណ៌មីខាងខ្នើត ខែពិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ឯណោះហោង ។*

*(តពីនេះទៅ ត្រូវបកសករាជប្រាប់ ថ្ងៃ ខែ ឆ្នាំ ដែលកន្លងហើយ និងបច្ចុប្បន្ន និងអនាគតដរាបដល់ចប់) ។*

# ប្រែពាក្យកាព្យ

យើងខ្ញុំបរិស័ទពុទ្ធសាសនា ឱនកាយវាចាចិត្តគោរព
ចំពោះព្រះពុទ្ធដែលជាម្លប់ គ្រប់គ្នាត្រូវចាំឲ្យទៀងទាត់ ។
ចងចាំថ្ងៃខែឲ្យបានច្បាស់ នៃព្រះពុទ្ធម្ចាស់គឺប្រវត្តិ
សង្ខេបខ្លីៗឲ្យរត់មាត់ កំណត់ចាំបានពេលទាំងអស់ ។
យាងចុះកាន់គភ៌ឆ្នាំរកា អាសាឍមាសាថ្ងៃព្រហស្បតិ៍
ប្រសូតឆ្នាំចថ្ងៃសុក្រស្មោះ ពិសាខឈើលាស់ដើមរដូវ ។
សោយរាជ្យកត្តិកថ្ងៃអាទិត្យ ប្រជុំព្រាហ្មណ៍ព្រឹទ្ធនាឆ្នាំឆ្លូវ
បួសថោះអាសាឍព្រហស្បតិ៍ត្រូវ ត្រាស់នៅរកាពិសាខពុធ ។
បរិនិព្វានទៅថ្ងៃអង្គារ បរិស័ទគ្រប់គ្នាកើតតក់ស្លុត
នៅខែពិសាខព្រះសម្ពុទ្ធ រលត់បញ្ចក្ខន្ធនាឆ្នាំម្សាញ់ ។
យើងបាត់ព្រះពុទ្ធទាន់សាសនា ធម៌ជាអាចារ្យកុំគ្នាន់ក្នាញ់
អ្នកប្រព្រឹត្តធម៌ឈ្មោះស្រលាញ់ ចំពោះអង្គអញតថាគត ។
បំណាច់អ្នកកាន់ពុទ្ធសាសនា ត្រូវចាំសាវតារនៃព្រះពុទ្ធ
គឺថ្ងៃខែឆ្នាំឲ្យហ្មត់ចត់ ទើបបានកំណត់ជាពុទ្ធជន ។

# គោតមប្រវត្តិ

ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្ដាដ៏មានបុណ្យ
និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន ។
មកចាប់ផ្ទៃមាតា ស្រីស្រឹង្គារស្រស់កល្យាណ
កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។
ក្នុងថ្ងៃព្រហស្បតិ៍អា- សាឍមាសាពេញបូណ៌មី
រកាជាឆ្នាំថ្មី សុខសិរីដល់ជនា ។
កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
នៅដងព្រៃព្រឹក្សា ឈ្មោះហៅថាព្រៃសាលវន ។
កក្រើកផែនពសុធា មានទេវតារាប់រយពាន់
ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី ។
ឆ្នាំចវិសាខនា- ថ្ងៃសុក្រជាពេញបូណ៌មី
ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ ។
កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកស្នួយ អភិសេកនឹងស្រីង្គារ ។
នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។
កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី
អាសាឍពេញបូណ៌មី ក្សត្រាថ្លៃបានសុខា ។

ស្ដេចមានព្រះរាជបុត្រ បរិសុទ្ធភក្ត្រស្រស់ថ្លា
គួរឲ្យព្រះរាជា ស្ដេចចំពាក់ចិត្តពេកក្រៃ ។
តែទ្រង់បានកាត់ផ្ដាច់ ទ្រង់សម្រេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា ។
បើបិតាបានត្រាស់ វិលរហ័សរកបុត្រា
មកប្រោសស្ងួនពុំងា ចាកសង្សារណាបុត្រថ្លៃ ។
កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី
អាសាឍពេញបូណ៌មី ក្សត្រាថ្លៃចេញបព្វជ្ជា ។
កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
ធ្វើទុក្ករកិរិយា គ្មាននរណាធ្វើដូចអី ។
បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី
ជាថ្ងៃព្រះជិនស្រី មានសិរីឈ្មោះក្រុងមារ ។
ត្រាស់ដឹងបានពីរខែ ទ្រង់គ្មាន់គ្នេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា នាកណ្ដាលដងព្រឹក្សព្រៃ ។
គឺក្នុងឆ្នាំរកា អាសាឍមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្ដើមពោលស្ដីធម៌ទេសនា ។
ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្ដា មានរហូតដល់សព្វថ្ងៃ ។
នាថ្ងៃមួយនោះណា គួរសោកាណាម្ចាស់ថ្លៃ

គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ ។
គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
នៅចំពោះមុខមារ នាបាវាលចេតិយ ។
បីខែកន្លងទៅ មិនឈប់នៅឃើនយូរអី
ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា ។
គឺក្នុងឆ្នាំនោះឯង មានការជ្រេងតែមាសា
គឺខែវិសាខនា ថ្ងៃអង្គារពេញបូណ៌មី ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍
នឹកគុណព្រះមុនី សូត្រប្រវត្តិព្រះសាស្តា ។
សូមឲ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិអារ្យ ជាសាស្តាដ៏ពិសិដ្ឋ
សូមចាក់ផ្លុះធមិពិត សមដូចចិត្តប្រាថ្នាហោង ។

*(ដោយព្រះគ្រូ សាន-សុជា)*

## ពុទ្ធប្បវត្តិសង្ខេប-ងាយចាំ

| | |
|---|---|
| ចាប់-រ-អា-ព្រ | គឺចាប់បដិសន្ធិ ឆ្នាំរកា ខែអាសាឍ ថ្ងៃព្រហស្បតិ៍ |
| ប្រ-ច-ពិ-សុក្រ | គឺប្រសូត ឆ្នាំច ខែពិសាខ ថ្ងៃសុក្រ |
| រាជ-ឆ្លូវ-ក-អា | គឺសោយរាជ្យ ឆ្នាំឆ្លូវ ខែកត្តិក ថ្ងៃអាទិត្យ |
| បួស-ថោះ-អា-ព្រ | គឺចេញបួស ឆ្នាំថោះ ខែអាសាឍ ថ្ងៃព្រហស្បតិ៍ |
| ត្រាស់-រ-ពិ-ពុធ | គឺត្រាស់ដឹង ឆ្នាំរកា ខែពិសាខ ថ្ងៃពុធ |
| ដាក់-ម្សាញ់-មា-អា | គឺដាក់អាយុសង្ខារ ឆ្នាំម្សាញ់ ខែមាឃ ថ្ងៃអាទិត្យ |
| និ-ម្សាញ់-ពិ-អ | គឺចូលនិព្វាន ឆ្នាំម្សាញ់ ខែពិសាខ ថ្ងៃអង្គារ |


ព្រះពុទ្ធ៥ព្រះអង្គ

## បទសរភញ្ញ

សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេវតា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។
ចង្អុលឲ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយបាត់ អាចកាត់សង្សារទុក្ខបាន ។
សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបុរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលំអានបានក្តីសុខ ។
ឥតមានសុខណាស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខនឹងមានព្រោះធម៌ស្ងប់ ។
ខ្ញុំសូមបង្គំផ្តោះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរតន៍គួរគោរព ជាម្លប់ត្រជាក់នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្តា
សូមគុណត្រៃរតន៍ជួយខេមរា ឲ្យបានសុខាតរៀងទៅ ។

*( ព្រះរាជនិពន្ធ សម្តេចសង្ឃរាជ ជួន-ណាត )*

# បទបង្ហូតទង់ព្រះពុទ្ធសាសនា

១. សូមមើលទង់ជ័យឆព្វណ្ណរង្សី  ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហមព្រមទាំងពណ៌ស  ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក ។
២. ប្រទេសតូចធំ បានស្មគ្រស្មាគម  ប្រជុំគ្នាច្រើនអនេក
ព្រមយករស្មីព្រះពុទ្ធគួរត្រេក  ប្រសើរពន់ពេកក្រៃកន្លង ។
៣. ធ្វើជាសញ្ញាទង់ជ័យសាសនា  នៃសម្ពុទ្ធធំ ចម្បង
ចូរយើងរាល់គ្នាយកចិត្តចាំចង  នឹកដល់ព្រះអង្គជាអម្ចាស់ ។
៤. ទោះជាតិផ្សេងគ្នាក៏ត្រូវដឹងថា  សុទ្ធសឹងតែជាពុទ្ធសាសន៍
ត្រូវមានសាមគ្គីទាំងក្មេងទាំងចាស់  ប្រឹងប្រែងឲ្យណាស់គ្រប់ៗ គ្នា ។
៥. សូមសាសនាពុទ្ធថ្កុំថ្កើងបំផុត  រុងរឿងវិសុទ្ធិ ថ្លៃថ្លា ហើយមាន
ជោគជ័យផ្សាយពេញលោកា  ដោយជនជ្រះថ្លាច្រើនសែនលាន។
៦. មានចិត្តស្នេហា គោរពបូជា  ចំពោះធម៌ ដ៏កល្យាណ
ទាំងមនុស្សទេវតាស្នេហាគ្រប់ប្រាណ  ប្រាថ្នាចង់បានសេចក្តីសុខ ។
៧. យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត  កាន់ធម៌នឹងបាន ផុតទុក្ខ
រួបរួមសាមគ្គីពីនេះទៅមុខ  យើងនឹងបានសុខក្សេមក្សាន្តត្រាណ ។
៨. ព្រមព្រៀងប្រព្រឹត្តកាន់ធម៌សុចរិត  ឆ្ពោះទៅកាន់ស្ថាននិព្វាន
ជាទីផុតទុក្ខបានសុខក្សេមក្សាន្ត  ជាតិយើងនឹងបានសោយសុខា ។

*( ព្រះរាជនិពន្ធ សម្តេចសង្ឃរាជ ជួន-ណាត )*

# បទឆព្វណ្ណរង្សី

## សូត្រពេលទង់បង្ហូតហើយ

១. ជាតិយើងអ្នកកាន់សាសនា    ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី    គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
២. ផ្សាយចេញពីព្រះកាយទ្រង់    រុងរឿងឫទ្ធិរុងប្រសើរបវរ
ឆ្កៀលឆ្វាត់កាយឆើតឆាយល្អ    ទាំង ៦ ពណ៌ស្រស់ល្អសោភា ។
៣. កំណើតនៃព្រះរស្មី    កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា    កាលដែលនៅជាព្រះពោធិសត្វ ។
៤. រស្មីពណ៌ខៀវនោះណា    កាលឆ្កៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត    កាលនៅជាក្សត្រនាមស្រីពិរាស្ត្រ
៥. រស្មីពណ៌លឿងភ្លឺថ្លា    កាលដែលទ្រង់អារសាច់ដៃធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស    ព្រះឥន្ទជាងមាសទ្រង់វៃបណ្ឌិត ។
៦. រស្មីក្រហមនោះណា    កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត    កាត់បេះដូងបិទធ្វើថ្នាំមាតា ។
៧. រស្មីពណ៌សសុទ្ធសាធ    កាលជាព្រះបាទវេស្សន្តរក្សត្រា
ឲ្យទានដំរីសសោភា    ដល់ព្រាហ្មណ៍ប្រាថ្នា យកពោធិញ្ញាណ ។
៨. រស្មីពណ៌ដូចជើងហង្ស    កាលមាតាទ្រង់យក្សចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ    ឲ្យយក្សសាមាន្យស៊ីប្តូរជីវិត ។
៩. រស្មីភ្លឺផ្លេកពណ៌ភាយ    កាលជាទន្សាយឈ្មោះសោមបណ្ឌិត

ឲ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតជាអត់អាហារ ។
១០. រស្មីខៀវលឿងក្រហម ស-ហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារចងចាំទុកអើយ ។

*( ព្រះរាជនិពន្ធ សម្តេចសង្ឃរាជ ជួន-ណាត )*

## កំណើតរស្មី ៦ ពណ៌

ពណ៌ខៀវកាលភ្លៀលព្រះនេត្រា ឲ្យឥន្ទព្រាហ្មណ៍ណាកាលជាក្សត្រ
នាមស្រីពិរាស្រ្តចង់សម្រេច ឲ្យបានសពេជ្ញសាស្តាចារ្យ ។
ពណ៌លឿងកាលអារសាច់ធ្វើមាស បិទលនអង្គព្រះពុទ្ធបដិមា
ព្រះឥន្ទ្រជាជាងច្នៃរចនា ថ្វាយពរសាធុការពេញផែនដី ។
ក្រហមជាពណ៌ឈាមបេះដូង ភ្លៀលពីដើមទ្រូងដោយឃ្មាតខ្មី
បិទពិសពស់ខាំព្រះជនី គង់រស់ជីវីជាស្បើយទៅ ។
ពណ៌សឲ្យទានដំរីស មង្គលបវរមាសធ្លិនធ្លៅ
ត្រូវរាស្រ្តបណ្តេញមិនឲ្យនៅ ព្រមទាំងកូនចៅភរិយាណា ។
ហង្សបាទលោហិតសាច់មំសំ អារសាច់ខ្លួនតាំងជួរមាតា
កាលយក្សវ៉ាចាប់បរិភោគ្គា ជីវិតមាតារស់រឹងខ្មី ។
ផ្លេកពណ្ណរាយកាលជាទន្សាយ ឲ្យទានពុំស្តាយជីវិតអី
លោតចូលភ្នក់ភ្លើងពុំថាអ្វី ឲ្យជាចំណីឥន្ទព្រាហ្មណ៍ណា ។
កាលដែលបានត្រាស់ជាព្រះពុទ្ធ ជាមកុដត្រៃភពក្នុងលោកា

ពណ៌ទាំង ៦ នេះសោភណា ក្លាយមកកើតជាឆព្វណ្ណរង្សី ។
ពេលនេះក្នុងលោកគេសន្មត យកពណ៌នេះកត់ជាសេចក្តី
ហៅទង់សាសនាព្រះជិនស្រី ពាសពេញផែនដីផ្ទៃពសុធា ។
យើងខ្ញុំពល់គ្នាសូមគោរព វន្ទាចមកពទង់សាសនា
សូមមានមង្គលឈ្នះមារា សត្រូវនានាក្នុងភពបី ។
សូមឲ្យយើងខ្ញុំប្រញាប់ដល់ ដើរកាត់តាមផ្លូវទៅបុរី
ជាស្ថានបរមសុខសួស្តី ដោយព្រះបារមីនិព្វានហោង ។

## សុខាភិយាចនគាថា

**បសន្នា ហោន្តុ សព្វេបិ បាណិនោ ពុទ្ធសាសនេ**
**សម្មា ធារំ បវេច្ឆន្តោ កាលេ ទេវោ បវស្សតុ**
**វុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនីំ**
**មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ**
**ឯវំ ធម្មេន រាជានោ បជំ រក្ខន្តុ សព្វទា ។**

ប្រែ: **បសន្នា ហោន្តុ សព្វេបិ បាណិនោ ពុទ្ធសាសនេ** សត្វទាំង-ឡាយទាំងពួង ចូរជ្រះថ្លាក្នុងព្រះពុទ្ធសាសនា,

**សម្មា ធារំ បវេច្ឆន្តោ កាលេ ទេវោ បវស្សតុ វុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនីំ** សូមឲ្យភ្លៀងបង្អូរនូវធារទឹកដោយប្រពៃ ចូរបង្អុរចុះក្នុងកាលដ៏គួរ ចូរបណ្តាលឲ្យផែនដីសំរឹទ្ធិ គឺថាឲ្យមានដីជាតិល្អឡើង ដើម្បីឲ្យកើតសេចក្តីចម្រើនដល់សត្វទាំងឡាយ,

**មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ** *មាតាក្តី បិតាក្តី បីបាច់រក្សាជានិច្ចនូវកូនតូចជាកូនបង្កើតយ៉ាងណាមិញ,*

**ឯវំ ធម្មេន រាជានោ បជំ រក្ខន្តុ សព្វទា** *សូមព្រះបរមក្សត្រទាំងឡាយ រក្សានូវប្រជាជនតាមគន្លងធម៌ ដូចជាមាតាបិតាបីបាច់រក្សានូវកូនដូច្នោះ ឲ្យបានសព្វកាលទៅហោង ។* ***(សម្តេច ជួន ណាត)***

## អធិដ្ឋានគាថា

**រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ**
**វុឌ្ឍឹ វិរុឡ្ហី បប្បោន្តុ សន្តិភាវញ្ច នាញ្ញថា ។**

*ដោយតេជះនៃព្រះរតនត្រ័យ សូមជនានុជនទាំងឡាយ*
*អ្នកនៅក្នុងកម្ពុជរដ្ឋ ដល់នូវការលូតលាស់ ចម្រើន*
*និង សន្តិភាព កុំបីឃ្លាតក្លាយទៅជាប្រការដទៃឡើយ ។*

***( បុរាណនិពន្ធ )***

# និគមនគាថា

**យំ សិទ្ធំ ឥមិនា បុញ្ញំ យញ្ចញ្ញំ បសុតំ មយា**
**ឯតេន បុញ្ញកម្មេន សីឃំ បប្បោមិ និព្វុតឹ**
**អប្បត្តោ យាវ និព្វានំ ភវេយ្យំ ជាតិជាតិយំ**
**មហាបញ្ញាយ សម្បន្នោ ជោតេយ្យំ ជិនសាសនំ**
**ឥមិនា រចនេន តុ សព្វេ សត្តា សុខី ហោន្តុ**
**កម្ពុជរដ្ឋវាសិនំ សន្តិភាវោ សទា ហោតុ ។**

*ដោយផលបុណ្យ ដែលសម្រេចពីការរចនានូវសៀវភៅនេះក្តី ដោយបុញ្ញកម្មដែលខ្ញុំបានសន្សំមកហើយក្តី សូមឲ្យខ្ញុំបានសម្រេចនូវព្រះនិព្វានដ៏ឆាប់រហ័ស ។ ប្រសិនបើមិនទាន់បានសម្រេចនូវព្រះនិព្វានដរាបណា ក៏សូមឲ្យខ្ញុំជាអ្នកដល់ព្រម ដោយប្រាជ្ញាដ៏ធំ អាចប្រកាសសាសនាព្រះជិនស្រីឲ្យរុងរឿងគ្រប់ៗជាតិ ។ ដោយការរចនាសៀវភៅនេះ សូមសព្វសត្វទាំងអស់ប្រកបតែសេចក្តីសុខ សូមសន្តិភាពកើតមានសព្វកាលទាំងពួង ដល់ប្រជាជនអ្នករស់នៅក្នុងដែនកម្ពុជា ។៚*

**ចប់**

# ឯកសារយោង

- ពុទ្ធប្បវត្តិ ទូរេនិទាន និង អវិទូរេនិទាន
- ពិធីពុទ្ធាភិសេក (សម្ដេចសង្ឃរាជ ជួន-ណាត)
- បាលីវេយ្យាករណ៍ (សេខ-នាង)
- អដ្ឋកថារតនសូត្រ បិដកលេខ ៥២
- សៀវភៅប្រវត្តិព្រះសារីរិកធាតុ (វ៉ាន់ ចាន់សារ៉ែន)
- គាថាធម្មបទ ពុទ្ធវគ្គ
- ឯកសារព្រះគ្រូម៉ី-ជួន និងលោកគ្រូ កែ-យឿង
- សៀវភៅ "គោរពគុណ" ឧបាសក ជួន-ម៉េន
- ឯកសារលោកអាចារ្យក្មេង ហេង-ជុំនិត
- វចនានុក្រមខ្មែរ បោះពុម្ពគ្រាទី ៥
- និងឯកសារមួយចំនួនទៀត

---

E-mai l: kolsopheap839@gmail.com
Facebook : Kol Sopheap
Page : Kol Sopheap - គល់-សុភាព
Contact : 088 26 94 695 / 016 75 30 89

រៀបរៀងដោយ
ភិក្ខុ អគ្គទត្តោ. គល់-សុភាព
ខែមិថុនា ឆ្នាំ ២០១៩
ខេត្តកំពង់ឆ្នាំង

# សៀវភៅដែលខ្ញុំបានរៀបរៀង

| | | |
|---|---|---|
| ១- | ភាសាខ្មែរ | (30-1-2007) |
| ២- | មហាធម្មសង្គហៈ | (23-7-2014) |
| ៣- | សង្គហគាថា | (4-1-2015) |
| ៤- | វេទមន្តខ្មែរ (ច្បាប់ចម្លង) | (3-7-2015) |
| ៥- | បាលីមន្ត្រគាថា | (30-10-2015) |
| ៦- | ប្រជុំតម្រា (ច្បាប់ចម្លង) | (29-7-2015) |
| ៧- | ក្បួនព្រហ្មជាតិ (ច្បាប់ចម្លង) | (18-6-2015) |
| ៨- | ក្បួនកុមារជន់ (ច្បាប់ចម្លង) | (22-2-2016) |
| ៩- | ព្រហ្មជាតិកណ្ឌទី២ (ច្បាប់ចម្លង) | (22-2-2016) |
| ១០- | វិនយសង្គហៈ (ច្បាប់ចម្លង) | (9-1-2019) |
| ១១- | បព្វជ្ជាខន្ធកៈ (ច្បាប់ចម្លង) | (24-1-2019) |
| ១២- | ពិធីពុទ្ធាភិសេក | (12-6-2019 |
| ១៣- | អភិធម្មត្ថសង្គហៈ បរិច្ឆេទទី៥ | (26-12-2019) |
| ១៤- | នមស្ការព្រះរតនត្រ័យ | (1-6-2020) |
| ១៥- | KATHINA CEREMONY | (0-11-2020) |